

# ស្ថានភាពពន្ធនាគារនៅ កម្ពុជា
# ឆ្នាំ២០០៥ និង ២០០៦: ថ្ងៃមួយក្នុងជីវភាពរស់នៅជា...

ខ្ញុំបាទឈ្មោះដារ៉ារិទ្ធ អាយុ២៦ឆ្នាំ ហើយខ្ញុំរស់នៅក្នុងបន្ទប់ឃុំឃាំងពន្ធនាគារមួយ
ជាមួយនឹងទណ្ឌិតបុរស ២២នាក់ផ្សេងទៀត

របាយការណ៍
ខែមករា ២០០៧


លីកាដូ
LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
**LICADHO**
Cambodian League for the
Promotion and Defense of Human Rights

# ស្ថានភាពពន្ធនាគារនៅកម្ពុជាឆ្នាំ២០០៥ និង ២០០៦: ថ្ងៃមួយក្នុងជីវភាពរស់នៅជា...

*ខ្ញុំបាទឈ្មោះដារ៉ាវិទ្ធ អាយុ២៦ឆ្នាំ ហើយខ្ញុំរស់នៅក្នុងបន្ទប់ឃុំឃាំងពន្ធនាគារមួយ ជាមួយនឹងទណ្ឌិតបុរស ២២នាក់ផ្សេងទៀត.*

របាយការណ៍

ខែមករា ឆ្នាំ២០០៧

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា នឹងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និង ស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៧ របស់ខ្លួន ដូចខាងក្រោមៈ**

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារនឹងវិភាគអោយបានឆាប់រហ័ស។
- **ការិយាល័យអប់រំសិទ្ធិមនុស្ស** គឺជាការិយាល័យដែលបើកវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមគោលដៅនានាដូចជា មន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ ព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស នឹងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិក ដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយអោយពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និង មន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រនឹងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណ្ណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណ្ណកម្ម នឹងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណ្ណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្តាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា នឹងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី នឹងធ្វើការតស៊ូមតិ ដើម្បីអោយមានការផ្លាស់ប្តូរផ្នែកច្បាប់ និង សង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១

ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org

គេហទំព័រ: http://www.licadho.org/

**ក្របរូបភាពផ្នែកខាងមុខ:** *ផតក្នុងបន្ទប់ឃុំឃាំងអ្នកទោសក្នុងពន្ធនាគារតាខ្មៅ (មុនឆ្នាំ២០០៥ ក្រោយមកបន្ទប់នេះត្រូវបានជួសជុលឡើងវិញក្នុងឆ្នាំ២០០៦) ។*

របាយការណ៍នេះ បានរៀបចំឡើងក្រោមជំនួយហិរញ្ញវត្ថុរបស់គណៈកម្មាធិការសហគមន៍អឺរ៉ុប ។ ការពិពិណនាក្នុងរបាយការណ៍នេះជាការទទួលខុសត្រូវរបស់អង្គការលីកាដូ ដោយមិនឆ្លុះបញ្ចាំង ពីទស្សនៈរបស់គណៈកម្មធិការសហគមន៍អឺរ៉ុបឡើយ ។

# មាតិការឿង


**១. សេចក្ដីផ្ដើម ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១**

វិធីសាស្ត្រ ------------------------------------------------------------------ ១

**២. ផ្ទះរបស់ខ្ញុំក្នុងពន្ធនាគារ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤**

ករណីសិក្សាទី១: បន្ទប់ឃុំឃាំងក្នុងពន្ធនាគារ ------------------------------------------ ៤

ចំនួនទណ្ឌិត ------------------------------------------------------------------ ៦

ទីតាំងពន្ធនាគារ ដែលបានឃ្លាំមើលដោយអង្គការលីកាដូ ---------------------------------- ៨

តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ? ------------------------------------------------- ៨

**៣. ប្រាក់ ១.៥០០ រៀល របបសម្រាប់អាហារមួយថ្ងៃ ~~~~~~~~~~~~~~~~~~~~~~~~~~ ១០**

ករណីសិក្សាទី២: អាហារក្នុងពន្ធនាគារ ------------------------------------------- ១០

របបម្ហូបអាហារកំណត់ជាផ្លូវការនៅក្នុងពន្ធនាគារ -------------------------------------- ១១

តើអង្គការលីកាដូកំពុងបំរើសេវាធ្វើអ្វីខ្លះ? ------------------------------------------ ១២

**៤. តម្លៃចូលសួរសុខទុក្ខ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៤**

ករណីសិក្សា ទី៣: ការមកសួរសុខទុក្ខនៅពន្ធនាគារ ------------------------------------ ១៤

នីតិវិធីពន្ធនាគារ និង ភ្ញៀវ ---------------------------------------------------- ១៥

តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ? ------------------------------------------------ ១៦

**៥. ពេលវេលាកន្លង ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៧**

ករណីសិក្សា ទី៤ : ការធ្វើលំហាត់ប្រាណនៅក្នុងពន្ធនាគារ -------------------------------- ១៧

បទដ្ឋានអប្បបរិមារនៃអង្គការសហប្រជាជាតិស្ដីពីការធ្វើលំហាត់ប្រាណ ------------------------ ១៩

ឱយ៉ាក្រោមពន្ធនាគារ ---------------------------------------------------------- ១៩

**៦. នរណាចាំឃ្លាំមើលខ្ញុំ? ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ២២**

ករណីសិក្សាទី ៥: ឆ្មាំពន្ធនាគារ ------------------------------------------------- ២២

ឆ្មាំពន្ធនាគារ ----------------------------------------------------------------- ២៤

អំពើទារុណកម្ម --------------------------------------------------------------- ២៤

របាយការណ៍ករណីអំពើទារុណកម្ម ----------------------------------------------- ២៥

ទារុណកម្មនៅមន្ទីរឃុំឃាំងនគរបាល ---------------------------------------- ២៦

ទារុណកម្មនៅក្នុងពន្ធនាគារ ---------------------------------------------- ២៧

ការរត់គេចពីពន្ធនាគារ------------------------------------------------ ២៨

តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ? ----------------------------------------- ៣០

**៧. សុខភាពខ្ញុំ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣១**

ករណីសិក្សាទី ៦: សុខភាពនៅពន្ធនាគារ-------------------------------------- ៣១

ការស្លាប់នៅក្នុងពន្ធនាគារ ---------------------------------------------- ៣៣

តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ? ----------------------------------------- ៣៥

**៨.ការយល់ឃើញផ្សេងគ្នាចំពោះ ស្ត្រី កុមារ និង អនីតិជន~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៧**

ករណីសិក្សាទី ៧: ស្ត្រីក្នុងពន្ធនាគារ ---------------------------------------- ៣៧

ការឃុំឃាំងស្ត្រីដាច់ដោយឡែក------------------------------------------------៤០

ការរំលោភបៀតបៀនផ្លូវភេទ និង រូបរាងកាយ ---------------------------------------៤២

កុមារគ្មានទោសដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយ ------------------------------ ៤៣

ករណីសិក្សាទី ៨: អនីតិជនក្នុងពន្ធនាគារ -------------------------------------------៤៤

យុត្តិធម៌យុវជន -------------------------------------------------------------៤៧

តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ? ----------------------------------------------៤៨

# ១. សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ១៩៩៧មកអង្គការលីកាដូ បានចេញផ្សាយរបាយការណ៍ជាច្រើនស្តីពីស្ថានភាពពន្ធនាគារកម្ពុជា ដោយបានលើកឡើងពីកង្វល់ទាក់ទងនឹងសិទ្ធិមនុស្សដែលគួរឱ្យព្រួយបារម្ភជាច្រើន និងលើកជាអនុសាសន៍មួយចំនួន ដើម្បីផ្លាស់ប្តូរថែមទៀត។ ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យមួយ អង្គការលីកាដូ មានគោលបំណងសំខាន់ៗ មួយចំនួនដូចខាងក្រោមៈ

- ឃ្លាំមើលស្ថានភាពពន្ធនាគារកម្ពុជា និងសិទ្ធិរបស់ពិរុទ្ធជន និង ទណ្ឌិត
- បែងចែកព័ត៌មានឥតលំអៀង និង ប្រកបដោយគុណភាពខ្ពស់ដោយមិនប្រកាន់បក្សពួក
- ធ្វើការបញ្ចុះបញ្ចូល ដើម្បីឱ្យមានកំណែទម្រង់ប្រកបដោយភាពវិជ្ជមាន

របាយការណ៍នេះមានគោលបំណង បង្ហាញឱ្យមើលឃើញកាន់តែច្បាស់ពីស្ថានភាពរស់នៅជាក់ស្តែងដែលទណ្ឌិតកម្ពុជាបានប្រឈមមុខ។ ទិន្នន័យទាំងនេះបានដកស្រង់ពីសំដីផ្ទាល់របស់ទណ្ឌិត និង ពីការសង្កេត ហើយនិងដកស្រង់ចេញ ពីរបាយការណ៍អ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូ។ របាយការណ៍នេះត្រូវបានរៀបរាប់ដោយបុគ្គលទីមួយ ដែលប្រើអត្តសញ្ញាណប្រឌិត ដើម្បីការពារអនាមិកភាពបុគ្គលដែលជាមនុស្សបានផ្តល់ព័ត៌មានស្តីពីស្ថិតិបន្ថែមដែលទាក់ទងទៅនឹងបញ្ហាផ្សេងៗ។

យើងសង្ឃឹមថា របាយការណ៍នេះនឹងត្រូវបានប្រើប្រាស់ដោយមន្ត្រីរដ្ឋាភិបាល និង មន្ត្រីពន្ធនាគារ ក្រុមអ្នកតស៊ូមតិ អ្នកការពារសិទ្ធិមនុស្ស អ្នកស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ អង្គការផ្តល់មូលនិធិ ក៏ដូចជាអ្នកជំនាញផ្នែកច្បាប់ ដើម្បីជាឧបករណ៍ដោះស្រាយបញ្ហាដែលមានស្រាប់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពពន្ធនាគារ នឹងលើកកំពស់សិទ្ធិ ពិរុទ្ធជន និង ទណ្ឌិត។ របាយការណ៍នេះត្រូវបានចងក្រងដោយប្រមូលព័ត៌មានខ្លះពីរបាយការណ៍មួយចំនួនកាលពី ១០ ឆ្នាំមុន ក៏ដូចជាព័ត៌មានដែលទើបតែបានប្រមូលក្នុងឆ្នាំ២០០៥ និង ១០ខែដំបូងនៃឆ្នាំ២០០៦ នេះផងដែរ។

## វិធីសាស្ត្រ

ព័ត៌មានក្នុងរបាយការណ៍នេះ គឺជាលទ្ធផលមួយដែលទទួលបានមកពីការចូលរួម និងការខិតខំប្រឹងប្រែងរបស់កម្មវិធីពន្ធនាគារ និង ការិយាល័យពេទ្យនៃអង្គការលីកាដូ។ អ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ ទាំងអស់បានចុះស្រាវជ្រាវនឹងសម្ភាសន៍ទណ្ឌិត និង ពិរុទ្ធជន ៤ដងក្នុងមួយខែលើ ១៨ពន្ធនាគារ ក្នុងចំណោមចំនួន ២៥ពន្ធនាគារទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯការិយាល័យពេទ្យនៃអង្គការលីកាដូ បានចុះពិនិត្យនឹងព្យាបាលមួយ

ខែម្តងក្នុងពន្ធនាគារចំនួន ១២[១] ។ ក្នុងខែមករា ២០០៦ ស្ថាប័នពន្ធនាគារទាំង១៨ បានឃុំឃាំងជាអប្បរមា ៩០% នៃចំនួនសរុបទណ្ឌិត និង ពិរុទ្ធជនសញ្ជាតិជាតិកម្ពុជា[២] ។

[១] ដោយទាក់ទងទៅនឹងបញ្ហាថវិការ និងសំភារៈ អ្នកស៊ើបអង្កេត លីកាដូ ចុះទៅស្រាវជ្រាវ និងសម្ភាសន៍ទណ្ឌិតក្នុងពន្ធនាគារដែលនៅក្បែរការិយាល័យភ្នំពេញ និងការិយាល័យតាម បណ្តាខេត្តទាំង ១២ របស់ខ្លួនតែប៉ុណ្ណោះ។ ពន្ធនាគារទាំងនោះរួមមាន នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) មណ្ឌលអប់រំកែប្រែទី១ "ម-១" (អតីតគុក តេ ៣) មណ្ឌលអប់រំកែប្រែទី២ "ម-២" (សម្រាប់ឃុំឃាំង ទណ្ឌិតស្ត្រី និងអនីតិជន) មណ្ឌលអប់រំកែប្រែទី ៣ "ម-៣" (អតីតគុកត្រពាំងថ្លុង ឬ តេ ៥) ពន្ធនាគារយោធាទួលស្លែង តាខ្មៅ ក្រុងកំពង់សោម កំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង និងកោះកុង។ អ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ មិនបានបន្តឃ្លាំមើលនៅពន្ធនាគារ ខេត្តព្រៃវែង និងតាកែវទៀតទេ ទោះជាពន្ធនាគារទាំងនោះនៅជិតការិយាល័យលីកាដូក៏ដោយ។ ក្នុងខេត្តដែលគ្មានកាិយាល័យ លីកាដូ ដូចជាខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង តាកែវ និងព្រៃវែង លីកាដូមិនចុះទៅឃ្លាំមើលទេ។ សមាគមន៍សិទ្ធិមនុស្សកម្ពុជា និងអភិវឌ្ឍន៍ "អាដហុក" ជួបប្រជុំជាមួយប្រធានពន្ធនាគារដែលគ្មានការិយាល័យ លីកាដូ ហើយបានធ្វើការអធិការកិច្ច ក្នុងពេលកំណត់មួយ ទោះជាមិនមានអ្នកស្រាវជ្រាវពន្ធនាគារ និងក្រុមគ្រូពេទ្យជាអចិន្ត្រៃយ៍ក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យពេទ្យ លីកាដូ បានចុះទៅពិនិត្យ និងព្យាបាលក្នុងពន្ធនាគារមួយចំនួនដូចជា តាខ្មៅ កំពង់ចាម តាកែវ កំពង់ចាម ស្វាយរៀង ព្រៃវែង ប៉េហ្ស៊ី ទួលស្លែង កោះកុង ពោធិ៍សាត់ ក្រុងកំពង់សោម បាត់ដំបង និងកំពង់ធំ។ ចំណែកឯពន្ធនាគារមួយចំនួនទៀតត្រូវចុះទៅពិនិត្យ និងព្យាបាលដោយអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដូចជា "កម្មវិធីតាមដានពន្ធនាគារ" ជាដើម។

[២] ស្ថិតិ ៩០%នេះ គឺផ្អែកលើចំនួនទណ្ឌិតក្នុង ១៨ ពន្ធនាគារដែលត្រូវបានឃ្លាំមើល និងស្រាវជ្រាវដោយ លីកាដូ ដោយក្នុងខែមករា ២០០៦ មានទណ្ឌិតសរុបចំនួន ៨.៤៥៩ នាក់ និងចំនួនទណ្ឌិតសរុបទូទាំងព្រះរាជាណាចក្រកម្ពុជាមាន ៩.៣៧៣ នាក់ ដោយតួរលេខនេះផ្តល់ដោយ គំរោងជំនួយយុត្តិធម៌ឧក្រិដ្ឋជនកម្ពុជា។

*នៅក្នុងរបាយការណ៍នេះអត្ថបទរឿងរបស់ដារ៉ារិទ្ធ និង ទណ្ឌិតដទៃទៀត គឺជារឿងប្រឌិត តែទោះជាយ៉ាងណាក៏ដោយ ហេតុការណ៍ និងស្ថានភាពដែលបានរៀបរាប់ គឺពឹងផ្អែកលើស្ថានភាពជីវិតពិតរបស់ទណ្ឌិតជា ពិសេសទណ្ឌិតនៅមណ្ឌលអប់រំកែប្រែទី១ "ម-១"។*

*ព័ត៌មានដែលមានក្នុងអត្ថបទរឿងនីមួយៗ យើងទទួលបានតាមរយៈការសម្ភាសន៍ជាមួយទណ្ឌិត ការសង្កេត និងការចងក្រងឯកសាររបស់អ្នកស្រាវជ្រាវពន្ធនាគារលីកាដូ។ ពន្ធនាគារម-១ ត្រូវបានគេចាត់ទុកថា ជាពន្ធនាគារដែលធំជាងគេបំផុតក្នុងប្រទេសកម្ពុជា និងមានស្ថានភាពល្អប្រសើរជាងគេ ប្រសិនបើប្រៀបធៀបទៅនឹងពន្ធនាគារក្នុងក្រុងភ្នំពេញ និង តាមបណ្តាខេត្ត។ ម-១ មានទីតាំងនៅជាយ ក្រុងភ្នំពេញ និងសម្រាប់ឃុំឃាំងតែទណ្ឌិតបុរសប៉ុណ្ណោះ។*

*អត្ថបទខ្លីបន្តបន្ទាប់មានក្នុងរបាយការណ៍នេះ ដែលទាក់ទងទៅនឹងបទពិសោធន៍របស់ស្ត្រី និងកុមារក្នុងពន្ធនាគារ គឺផ្អែកលើការសម្ភាសន៍ ការចងក្រងឯកសាររបស់ពន្ធនាគារតាមបណ្តាខេត្តដែលមានទណ្ឌិតស្ត្រី និង កុមារទាំងនោះត្រូវបានគេឃុំឃាំងជាមួយទណ្ឌិតបុរស។*

*លីកាដូបានបង្កើតអត្ថបទខ្លីចំនួនបីដែលរៀបរាប់អំពីដំណើររឿងរបស់ទណ្ឌិតបុរស ទណ្ឌិតស្ត្រី និង អនីតិជន។ គោលបំណងនៃការបង្កើតរឿងនេះ គឺមិនមែនគ្រាន់តែធ្វើជាល្ខោនច្នៃប្រឌិតហួសហេតុប៉ុណ្ណោះទេ។ តែវាថែមទាំងផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងជីវិតពិតរបស់ទណ្ឌិតរស់នៅក្នុងពន្ធនាគារកម្ពុជាផងដែរ។*



*ល្ខោនស្រមោលខ្មែរ ពិពណ៌នាពីទណ្ឌិតម្នាក់*

# ២. ផ្ទះរបស់ខ្ញុំក្នុងពន្ធនាគារ

## ករណីសិក្សាទី១: បន្ទប់ឃុំឃាំងក្នុងពន្ធនាគារ

*ខ្ញុំបាទឈ្មោះដារ៉ារិទ្ធ អាយុ២៦ឆ្នាំ ហើយខ្ញុំរស់នៅក្នុងបន្ទប់ឃុំឃាំងក្នុងពន្ធនាគារមួយ ជាមួយនឹងទណ្ឌិតបុរស ២២នាក់ផ្សេងទៀត....*

*ខ្ញុំសំណាងល្អដោយសារតែខ្ញុំត្រូវបានគេឃុំឃាំងក្នុងបន្ទប់ដែលមានទំហំធំល្មមជាងបន្ទប់ដទៃទៀត ។ បន្ទប់នោះមានទំហំប្រហែលជា ៨ ម៉ែត្រការ៉េ ។ ខ្ញុំដឹងថាមានបន្ទប់ខ្លះមានទំហំត្រឹមតែ ៤ ម៉ែត្រការ៉េប៉ុណ្ណោះ ។ ប៉ុន្តែ បន្ទប់ធំ គឺមានន័យថានឹងមានទណ្ឌិតត្រូវដាក់បន្ថែមទៀត ។ ខ្ញុំបានឮថា ទណ្ឌិតអាចឱ្យលុយទៅឆ្មាំពន្ធនាគារ ដើម្បីបានរស់នៅក្នុងបន្ទប់ធំដែលមានទណ្ឌិតត្រឹមតែ២-៣នាក់ប៉ុណ្ណោះ ។ ខ្ញុំមិនមែនជាទណ្ឌិតម្នាក់ក្នុងចំណោមពួកគេ ព្រោះ គ្មានលុយច្រើនទេ ។*

*បន្ទប់របស់ខ្ញុំចង្អៀតណាស់ ។ ទណ្ឌិតទាំងអស់ត្រូវព្យួរសំភារៈផ្ទាល់ខ្លួនទៅនឹងជញ្ជាំង ឬ ព្យួរទៅនឹងធ្នើរខាងលើ ។ ធ្វើបែបនេះ ដើម្បីឱ្យបន្ទប់ទូលាយបន្តិចងាយស្រួលក្នុងការអង្គុយ ឬ ដេក ។ ទណ្ឌិតខ្លះសំណាង ដោយសារតែគាត់មានអង្រឹង និង មុងផ្ទាល់ខ្លួនរបស់គាត់ ។ ពួកគាត់មានទាំងលុយ មានទាំងក្រុមគ្រួសាររបស់គាត់ដែលអាចផ្តល់សំភារៈទាំងនេះជូនគាត់ ។ នៅក្នុងពន្ធនាគារ ប្រសិនបើអ្នកគ្មានលុយ ឬ សាច់ញាតិ និង ក្រុមគ្រួសារដែលចិត្តល្អទេ នោះអ្នកនឹងគ្មានផ្លូវទទួលបានសំភារៈទាំងនោះឡើយ ។*

*រៀងរាល់ថ្ងៃ យើងអាចសំអាតបន្ទប់របស់យើងជាមួយនឹងទឹក ប៉ុន្តែ នៅចុងសប្តាហ៍ពួកយើងមិនសំអាតទេ ។ ក្នុងបន្ទប់ពិតជាមិនស្អាត ហើយមានតែបង្អួចតូចមួយប៉ុណ្ណោះសម្រាប់ខ្យល់ចេញចូល ។ បរិយាកាសក្តៅ ស្អុយ គគ្រិច និង សើមទៀតផង ។ នៅក្នុងបន្ទប់មានតែបង្គន់តូចមួយប៉ុណ្ណោះ ហើយគ្មានបណ្តាញទឹកស្អាត គឺមានតែអាងទឹកធំៗពីរ ដែលឆ្មាំពន្ធនាគារបានបូមទឹកដាក់ឱ្យប្រើប្រាស់ ។ ពួកយើងបានយកទឹកនេះទៅប្រើប្រាស់ក្នុងបង្គន់ សម្រាប់បោកគក់សម្លៀកបំពាក់នឹងសម្រាប់ងូត ។*

*បន្ទប់ពន្ធនាគារត្រូវបានបែងចែកសម្រាប់ទណ្ឌិត និង ពិរុទ្ធជន (អ្នកដែលរង់ចាំជំនុំជំរះនៅតុលាការ) ។ មានទណ្ឌិតជាច្រើននាក់ក្នុងបន្ទប់នីមួយៗ ។ ពួកយើងទាំងអស់គ្នាត្រូវបានគេញាត់បញ្ចូលក្នុងបន្ទប់ដ៏សែនចង្អៀត ហើយពួកយើងពិបាកក្នុងការដកដង្ហើម ។ ទណ្ឌិតខ្លះបានត្អូញត្អែរប្រាប់ឆ្មាំពន្ធនាគារ តែពួកគេមិនដែលចាប់អារម្មណ៍ពីបញ្ហានេះឡើយ ។ ខ្ញុំមិនគិតថា មានរឿងជាច្រើនដែលពួកគេអាចធ្វើ ឬចង់ធ្វើ ។ គ្មាននណាម្នាក់ព្រួយបារម្ភពីពួកយើងដែលជាទណ្ឌិតនោះទេ ។ ដោយសារតែមានទណ្ឌិតច្រើនពេកក្នុងបន្ទប់ពេញមួយថ្ងៃៗ ឬ ពេលខ្លះ ដោយសារតែមានអារម្មណ៍អផ្សុក ឬ ពិបាកក្នុងការទ្រាំពេកវាធ្វើឱ្យពួក*

យើងមានជម្លោះ ឬ វាយគ្នាក៏មាន ។ ខ្ញុំមិនអាចចាំបាននៅពេលវេលាចុងក្រោយដែលខ្ញុំនៅតែម្នាក់ឯង ។

នៅក្នុងបន្ទប់របស់ខ្ញុំមានអ្នកដឹកនាំម្នាក់ ។ គ្រប់បន្ទប់ទាំងអស់សុទ្ធតែមានមេដឹកនាំ ។ ឆ្មាំពន្ធនាគារ ឬ នាយកពន្ធនាគារអាចជ្រើសរើសទណ្ឌិតម្នាក់ឱ្យធ្វើជាមេដឹកនាំបន្ទប់នីមួយៗបាន (ប្រសិនបើពួកគេពេញចិត្តនរណាម្នាក់) ប៉ុន្តែមេដឹកនាំបន្ទប់ដែលតែងតាំងដោយសារតែពួកគេចំណាយលុយទៅឱ្យឆ្មាំពន្ធនាគារ ឬ នាយកពន្ធនាគារ ។ ភាគច្រើន អ្នកចំណាយលុយតែម្តងប៉ុណ្ណោះ តែប្រសិនបើអ្នកមានសំណាងអាក្រក់ អ្នកត្រូវតែចំណាយលុយម្តងទៀត ។ ប្រសិនបើអ្នកក្លាយជាមេដឹកនាំបន្ទប់ នោះអ្នកនឹងមានពេលសំរាកបានច្រើន ហើយអ្នកមិនចាំបាច់អង្គុយក្នុងបន្ទប់ពេញមួយថ្ងៃទេ ហើយអ្នកនឹងក្លាយទៅជាអ្នកគ្រប់គ្រងបន្ទប់ដែលអាចបញ្ជាទណ្ឌិតនៅក្នុងបន្ទប់ឱ្យធ្វើអ្វីក៏បានដែរ ។ គ្មាននរណាម្នាក់ចូលចិត្តមេដឹកនាំបន្ទប់នោះទេ ដោយសារតែទណ្ឌិតទាំងអស់ដឹងថា គាត់រាយការណ៍ទៅឆ្មាំពន្ធនាគារនឹងប្រាប់ឆ្មាំពន្ធនាគារនូវបញ្ហាដែលកំពុងតែកើតមានឡើងក្នុងបន្ទប់ ។

ទណ្ឌិតថ្មីៗត្រូវបានគេបញ្ជូនមកស្ទើរតែរៀងរាល់ខែ ។ ខ្ញុំតែងតែមានអារម្មណ៍អាណិតអាសូរចំពោះទណ្ឌិតថ្មីទាំងនោះ ហើយខ្ញុំមិនចង់ចងចាំពេលវេលានោះទេ ។ ឆ្មាំពន្ធនាគារ និង មេដឹកនាំបន្ទប់ប្រព្រឹត្តទៅលើអ្នកដូចជាទាសករ ហើយពួកគេបញ្ជាឱ្យអ្នកធ្វើគ្រប់អ្វីទាំងអស់ដែលគេចង់បាន ។ អ្នកមិនត្រូវអនុញ្ញាតឱ្យយកសំភារៈចូលក្នុងបន្ទប់ ក្រៅពីសំលៀកបំពាក់ដែលអ្នកកំពុងតែស្លៀកឡើយ ។ ទណ្ឌិតថ្មីភាគច្រើនតែងតែទទួលនូវការស្វាគមន៍ដោយការវាយដំពីឆ្មាំពន្ធនាគារ ឬ មេដឹកនាំបន្ទប់ ។ ខ្ញុំនៅតែចងចាំនៅក្នុងចិត្តជានិច្ច ។ ខ្ញុំគិតថាការវាយដំនេះ គឺជាសញ្ញាបង្ហាញប្រាប់ថាទីនេះ គឺជាផ្ទះថ្មីរបស់អ្នក ហើយជីវិតរបស់អ្នកនឹងមិនងាយស្រួលទៀតឡើយ.......

## ចំនួនទណ្ឌិត

ក្នុងខែតុលា ឆ្នាំ២០០៦ ពន្ធនាគារទាំង១៨ មានទណ្ឌិតបុរសសរុប ៧.៨៤៧នាក់ ទណ្ឌិតស្រ្តីសរុប ៥៣៦ នាក់ និង អនីតិជនសរុប ៤៥២នាក់។ នេះបញ្ជាក់ថាចំនួនទណ្ឌិតកើនឡើងជាលំដាប់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

ចំនួនទណ្ឌិតក្នុងពន្ធនាគារទាំង១៨ ដែលបានចុះស្រាវជ្រាវដោយលីកាដូ ពីឆ្នាំ ១៩៩៩-២០០៦[៣]




| | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|---|---|---|---|---|
| ចំនួនទណ្ឌិត | ៣២៨២ | ៤៥០៩ | ៤៩៤២ | ៥៣០២ | ៥៧១១ | ៦២៩៦ | ៨២៣៨ | ៨៨៣៥ |
| អនីតិជន | ១២៨ | ២០៥ | ២២៣ | ២៧៣ | ២៩២ | ៣២៨ | ៤៤៧ | ៤៥២ |

ក្នុងឆ្នាំកន្លងទៅពន្ធនាគាមួយចំនួនត្រូវបានផ្លាស់ប្តូរទីតាំង នឹងជួសជុលថ្មី ដូចជា :

- **ខេត្តបាត់ដំបង:** ពន្ធនាគារត្រូវបានផ្លាស់ទៅទីតាំងថ្មីដែលមានចម្ងាយ ៤ គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង។ ពន្ធនាគាថ្មីនេះត្រូវបានសាងសង់រួចជាស្ថាពរនៅក្នុងខែធ្នូ ឆ្នាំ២០០៥។
- **ខេត្តកំពង់ចាម:** ពន្ធនាគារនេះត្រូវបានផ្លាស់ទៅទីតាំងថ្មីដែលមានចម្ងាយ ១០ គីឡូម៉ែត្រពីទីរួមខេត្ត កំពង់ចាម ហើយត្រូវបានសាងសង់រួចជាស្ថាពរនៅក្នុងខែមិនា ឆ្នាំ២០០៦។
- **នគរបាលយុត្តិធមិ (ប៉េហ្ស៊ី ភ្នំពេញ):** ក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ អគាររដ្ឋបាលរបស់ពន្ធនាគារនេះត្រូវបាន រុះរើចេញបន្ទាប់ពីដីនេះត្រូវលក់ទៅឱ្យក្រុមហ៊ុនឯកជនមួយ។ ទណ្ឌិតនៅតែត្រូវបានគេឃុំឃាំងនៅទីនោះ

[៣] តួរលេខសរុបរាប់បញ្ចូលទាំងនីតិជន និងអនីតិជន ទណ្ឌិត និងពិរុទ្ធជន ទណ្ឌិតបុរស និងស្ត្រី។ តួរលេខទាំងអស់គឺក្នុងខែធ្នូគ្រប់ឆ្នាំទាំងអស់ លើកលែងតែឆ្នាំ ២០០៦ គឺរាប់ត្រឹមខែតុលា ២០០៦។ តួរលេខឆ្នាំ ២០០២ គឺផ្អែកខ្លះផ្អែកលើការប៉ាន់ស្មានចំនួនទណ្ឌិតក្នុងមណ្ឌលអប់រំកែប្រែទី៣ "ម-៣" ដែលលីកាដូមិនបានចុះទៅស្រាវជ្រាវក្នុងឆ្នាំនោះ។

នឹងត្រូវផ្លាស់ទៅឃុំឃាំងនៅពន្ធនាគារថ្មីនៅពេលដែលត្រូវបានសាងសង់នៅជាយក្រុងភ្នំពេញ។

- **តាខ្មៅ :** ក្រោមជំនួយរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) ពន្ធនាគារនេះត្រូវបានជួសជុលទាំងស្រុង ហើយបានបើកឱ្យប្រើប្រាស់កាលពីខែវិច្ឆិកា ២០០៦។

ថ្វីបើមានការផ្លាស់ប្តូទីតាំងថ្មី និងមានការជួសជុលថ្មីក៏ដោយ តែស្ថានភាពពន្ធនាគារកម្ពុជាភាគច្រើននៅតែមានភាពចង្អៀតខ្លាំងដដែល។

**លទ្ធភាពពន្ធនាគាទាំង ១៨ សម្រាប់ដាក់ទណ្ឌិតដែលបានឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ២០០៤ និង ២០០៦**

| ពន្ធនាគារ | លទ្ធភាពពន្ធនាគារ ២០០៦ | ចំនួនទណ្ឌិត តុលា ២០០៦ | លទ្ធភាព | |
|---|---|---|---|---|
| | | | ធ្នូ ២០០៤ | វិច្ឆិកា ២០០៦ |
| ប៉េហ្ស៊ី | ១០០ | ១៥១ | ៧៤% | ១៥១% |
| ម-១ | ១.៥០០ | ២.១៣២ | ១០៧% | ១៤២% |
| ម-២ | ៣៥០ | ៥៤១ | ១០៤% | ១៥៥% |
| ម-៣ | ១.២០០ | ១.២៣៤ | ៦៩% | ១០៣% |
| ទួលស្លែង | ៥ | ៤ | ៨០% | ៨% |
| តាខ្មៅ | ៣៥០ | ៥៩៩ | ១៥៤% | ១៧១% |
| ក្រុងកំពង់សោម | ១០០ | ១៤៤ | ១០៩% | ១៤៤% |
| កំពង់ស្ពឺ | ២០០ | ២៤២ | ១០២% | ១២១% |
| កំពត | ១៨០ | ២៣២ | ៨៧% | ១២៩% |
| កំពង់ឆ្នាំង | ១២០ | ១៩១ | ១១៣% | ១៥៩% |
| កំពង់ចាម | ៤០០ | ៤៩៩ | ១០៥% | ១២៥% |
| កំពង់ធំ | ៦០ | ១២៦ | ២៣៥% | ២១០% |
| កោះកុង | ១៤០ | ១២០ | ១១៥% | ៨៦% |
| ពោធិ៍សាត់ | ១០០ | ១២២ | ៧៩% | ១២២% |
| បាត់ដំបង | ៦០០ | ៨៩៤ | ២៩០% | ១៤៩% |
| បន្ទាយមានជ័យ | ២០០ | ៤៧១ | ១៩០% | ២៣៦% |
| សៀមរាប | ៥៥០ | ៩២០ | ១១០% | ១៦៧% |
| ស្វាយរៀង | ២១០ | ២១៣ | ៨២% | ១០១% |
| **សរុបជាមធ្យម** | **៦.៤១០** | **៨.៨៣៥** | **១២៣%** | **១៣៨%** |

## ទីតាំងពន្ធនាគារ ដែលបានឃ្លាំមើលដោយអង្គការលីកាដូ




## តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ?

អ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ ប្រចាំក្រុងភ្នំពេញបានចុះទៅស្រាវជ្រាវនឹងសម្ភាសន៍ទណ្ឌិត និង ពិរុទ្ធជនក្នុងពន្ធនាគារទាំង៤ (ម-១ ម-២ តាខ្មៅ និង ប៉ៃហ្ស៊ី) រៀងរាល់មួយសប្តាហ៍ម្តង។ ចំណែកឯអ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ តាមបណ្តាខេត្តបានចុះទៅសម្ភាសន៍ទណ្ឌិត និង ពិរុទ្ធជនរៀងរាល់មួយសប្តាហ៍ម្តងផងដែរ។

រៀងរាល់ការចុះទៅសម្ភាសន៍ត្រូវប្រើរយៈពេលយ៉ាងច្រើនចាប់ពី ២-៣ ម៉ោង អ្នកស្រាវជ្រាវពន្ធនាគារបានសម្ភាសន៍ទណ្ឌិត និង ពិរុទ្ធជន ២-៤ នាក់ ដោយប្រើកម្រងសំណួរជាបទដ្ឋានមួយ ដែលចងក្រងស្តីពីព័ត៌មានលំអិត ការប្រព្រឹត្តិ ស្ថានភាពរស់នៅ ពាក្យបណ្តឹង ព័ត៌មានទាក់ទងខាងផ្លូវច្បាប់ (ការចាប់ខ្លួន ការឃុំខ្លួន សវនាការ ការផ្តន្ទាទោស និង មេធាវី) និង ព័ត៌មានសំខាន់ផ្សេងៗទៀតរបស់ទណ្ឌិត។ ជាធម្មតា ការសម្ភាសន៍ត្រូវបានធ្វើឡើងនៅក្នុងទីកន្លែងសម្ភាសន៍មួយ ដែលអាចជាបន្ទប់មួយ ឬ ទីធ្លាខាងក្រៅបន្ទប់ឃុំឃាំងដែលមានតុមួយ កៅអីមួយ នឹងមានវត្តមានអ្នកតំណាងឆ្មាំពន្ធនាគារម្នាក់ផងដែរ។ដោយសារតែមានវត្តមានឆ្មាំពន្ធនាគារ ឬ ទណ្ឌិត និង ពិរុទ្ធជនដទៃទៀតនៅទីនោះ ហេតុដូច្នេះ ការសម្ងាត់មួយចំនួនមិនអាចធានាបានឡើយ ទោះជាអ្នកស្រាវជ្រាវពន្ធនាគារ ស្វែងរកកន្លែង ដែលអាចសម្ភាសន៍ជាលក្ខណៈបុគ្គលក៏ដោយ។ រាល់ការចុះទៅសម្ភាសន៍ទាំងអស់ត្រូវតែរៀបចំទុកជាមុន រីឯទណ្ឌិតទាំងអស់ត្រូវបានជ្រើសរើសពីបញ្ជីឈ្មោះទណ្ឌិត ដែលអាចរកបាននៅការិយាល័យរដ្ឋបាលនៃពន្ធនាគារនិមួយៗ។

រៀងរាល់ ៦ខែម្តង លីកាដូបានដាក់ពាក្យស្នើរសុំទៅនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដើម្បីសុំការអនុញ្ញាតិឱ្យអ្នកស្រាវជ្រាវពន្ធនាគារចុះទៅស្រាវជ្រាវនឹងសម្ភាសន៍ទណ្ឌិតក្នុងពន្ធនាគារទាំង ១៨ និង ក្រុមគ្រូពេទ្យលីកាដូ បានចុះទៅពិនិត្យនឹងផ្តល់ការព្យាបាលទណ្ឌិតក្នុងពន្ធនាគារទាំង ១២។ លិខិតអនុញ្ញាតិនេះធ្វើឱ្យអ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ អាចចេញចូលពន្ធនាគារក្នុងកំឡុងពេលនោះ។ ទោះជាយ៉ាងណាក្តី ពេលខ្លះអ្នកស្រាវជ្រាវពន្ធនាគារត្រូវបានបដិសេធមិនឱ្យចូលទៅសម្ភាសន៍ទណ្ឌិតដោយសំអាងលើហេតុផលមួយចំនួន ដូចជា ការលួចរត់ចេញពីពន្ធនាគារ បញ្ហាអសន្តិសុខ ឥទ្ធិពលនយោបាយ ឬ ការហាមឃាត់របស់នាយកពន្ធនាគារជាដើម។



អ្នកស្រាវជ្រាវពន្ធនាគារ លីកាដូ ខែមិថុនា ឆ្នាំ២០០៦។ គេមិនអាចធានារក្សាការសម្ងាត់បានទេ នៅពេលដែលមានវត្តមានឆ្មាំពន្ធនាគារ និង ទណ្ឌិតដទៃទៀតស្ថិតនៅក្បែរ។

# ៣. ប្រាក់ ១.៥០០ រៀល របបសម្រាប់អាហារមួយថ្ងៃ

## ករណីសិក្សាទី២: អាហារក្នុងពន្ធនាគារ

*រៀងរាល់ថ្ងៃខ្ញុំភ្ញាក់ពីព្រឹកព្រហាមដោយពោះទទេ។ ខ្ញុំឃ្លានខ្លាំងណាស់ តែខ្ញុំស៊ាំទៅនឹងស្ថានភាពបែបនេះហើយ។*

*នៅក្នុងពន្ធនាគាយើងទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ គឺថ្ងៃត្រង់ និង ពេលល្ងាច។*

*អាហារថ្ងៃត្រង់ចាប់ផ្តើមនៅម៉ោង ១០.៣០នាទីព្រឹក និង ពេលល្ងាចនៅម៉ោង៤.៣០នាទី។ កណ្តឹងរោទិ៍ជាសញ្ញាប្រាប់យើងថា វាជាពេលហូបបាយហើយ។ មេដឹកនាំបន្ទប់នឹងទៅយកអាហារ ដើម្បីចែកឱ្យទៅទណ្ឌិតគ្រប់គ្នាក្នុងបន្ទប់ឃុំឃាំង។ យើងទាំងអស់គ្នាហូបអាហារនៅក្នុងបន្ទប់ឃុំឃាំង។ គ្មានចានសម្រាប់ដាក់អាហារទេ ដូច្នេះ អ្នកត្រូវតែទិញចានពីឆ្មាំពន្ធនាគារ ឬ ទទួលបានមកពីក្រុមគ្រួសារ ឬ ខ្ចីពីទណ្ឌិតដូចគ្នា។*

*ទណ្ឌិតមួយចំនួនត្រូវបានជ្រើសរើស ឬក៏សូកឆ្មាំពន្ធនាគារ ដើម្បីធ្វើជាចុងភៅនៅពន្ធនាគារ។ ប្រសិនបើ អ្នកក្លាយជាចុងភៅនៅពន្ធនាគារ អ្នកនឹងទទួលបានពេលវេលាច្រើននៅក្រៅបន្ទប់ឃុំឃាំង។ ជាធម្មតាអាហាររបស់ពួកយើងដដែលៗ គឺសម្លមួយចាន និង បាយមួយចាន។ អាហារនេះមិនសូវមានរសជាតិនឹងមិនមានបរិមាណគ្រប់គ្រាន់សម្រាប់ពួកយើងឡើយ។ រាល់ថ្ងៃ ពួកយើងឃ្លានខ្លាំងណាស់ ដូច្នេះ រាងកាយទណ្ឌិតដូចពួកយើងភាគច្រើនមានរាងស្គមស្គាំង។*

*សម្រាប់ទណ្ឌិតសំណាងល្អ ដែលមានលុយនឹងមានក្រុមគ្រួសារមកសួរសុខទុក្ខ ពួកគេអាចទិញអាហារបន្ថែមពីឆ្មាំពន្ធនាគារ ឬ ពួកគេទទួលពីក្រុមគ្រួសាររបស់ពួកគេ។ ពួកគេទទួលអាហារដែលពួកគេអាចយកមកចំអិន ដោយខ្លួនឯង ឬ ពេលខ្លះវាគ្រាន់តែជាអាហារសំរន់ប៉ុណ្ណោះ។ ពួកគាត់ចំអិនអាហារនៅក្នុងបន្ទប់ឃុំឃាំង ឬ នៅខាងក្រៅ ប្រសិនបើពួកគាត់មានពេលលំហាត់ប្រាណគ្រប់គ្រាន់។ ប្រសិនបើអ្នកចង់ចំអិនអាហារដោយខ្លួនឯង អ្នកត្រូវចំណាយលុយបន្ថែមទៀត ពីព្រោះអ្នកត្រូវទិញឧស ឬ ធ្យូងពីឆ្មាំពន្ធនាគារ។ ពេលខ្លះ ទណ្ឌិតដែលមានអាហារបន្ថែម បានចែករំលែកអាហាររបស់គេឱ្យទៅទណ្ឌិតនៅក្នុងបន្ទប់រស់នៅជាមួយគ្នា ដែលជាអ្នកគ្មានគ្រួសារមកសួសុខទុក្ខ។*

*អ្នកប្រាកដជាអាចដឹងថា តើទណ្ឌិតមួយណាមានលុយ ឬមានក្រុមគ្រួសារមកសុខទុក្ខ ពីព្រោះពួកគេមានរូបរាងធាត់ជាងទណ្ឌិតដទៃទៀតនឹងមិនមានរូបរាងស្គមស្គាំងដូចជារូបខ្ញុំនោះទេ។*

*ជាធម្មតា ពួកយើងហូបទឹកភ្លៀង ឬ ទឹកអាងក្នុងពន្ធនាគារ។ គ្រប់បន្ទប់ឃុំឃាំងទាំងអស់មានធុងដាក់ទឹកពីរ ដែលយើងអាចប្រើប្រាស់វាសម្រាប់ដងទឹក។ ពួកយើងស៊ាំទៅនឹងទឹកប្រភេទនេះហើយ ហើយខ្ញុំមិនគិតថាវាធ្វើឱ្យពួកមានជម្ងឺឡើយ។ ប៉ុន្តែ នៅក្នុងពន្ធនាគារ អ្នកមិនអាចដឹងប្រាកដថាតើអាចមានអ្វីខ្លះធ្វើឱ្យអ្នកឈឺនោះទេ។ ប្រសិនបើ ទណ្ឌិតមានលុយ ពួកគេអាចទិញទឹកបរិសុទ្ធពីឆ្មាំពន្ធនាគារ ប៉ុន្តែពួកឆ្មាំពន្ធនាគារលក់ឱ្យអ្នកក្នុងតម្លៃទ្វេដង។ ជាធម្មតា នៅខាងក្រៅទឹកបរិសុទ្ធមួយដបតម្លៃ ៥០០ រៀល ប៉ុន្តែ នៅទីនេះវាមានតម្លៃពី១.០០០ ទៅ ១.៥០០ រៀល។ វាហាក់ដូចជាមិនយុត្តិធម៌សោះ។*

*វាគឺជាបញ្ហាពិតនៅទីនេះ។ ប្រសិនបើអ្នកគ្មានលុយបន្ថែម ឬ សាច់ញាតិទេ នោះអ្នកនឹងគ្មានពេលទទួលបានអាហារ និង ទឹកសម្រាប់ហូបគ្រប់គ្រាន់ឡើយ នោះអ្នកនឹងឃ្លាន ស្រេកទឹកជារៀងរហូត។ ខ្ញុំមិនមានសាច់ញាតិ ឬក្រុមគ្រួសារនៅជិតឡើយ ហើយខ្ញុំក៏មិនមានលុយដែរ ហេតុដូច្នេះ វាពិបាកខ្លាំងណាស់សម្រាប់រូបខ្ញុំ....*



## របបម្ហូបអាហារកំណត់ជាផ្លូវការនៅក្នុងពន្ធនាគារ

ក្រសួងមហាផ្ទៃបានផ្តល់ប្រាក់ដល់គ្រប់នាយកដ្ឋានពន្ធនាគារទាំងអស់ ដែលអ្នកទោសម្នាក់ៗទទួលបានប្រាក់ចំនួន ១.៥០០ រៀល ( ០,៣៨ ដុល្លារ) ក្នុងមួយថ្ងៃ។ ប្រាក់ដែលផ្តល់នេះមិនមែនសំរាប់តែថ្លៃម្ហូបអាហារប៉ុណ្ណោះទេ ប៉ុន្តែបូករួមទាំងថ្លៃចំណាយផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងអ្នកទោស។ ថ្លៃចំណាយរួមមាន ថ្លៃធ្វើដំណើរ អនាម័យ ឧស្ម័នចំហេះ (អុស) ទឹក អគ្គីសនី និងការងាររដ្ឋបាល។ ជាការពិតណាស់ ប្រាក់បន្តិចបន្តួចនេះស្ទើរតែពុំអាចចំណាយលើថ្លៃម្ហូបអាហារសំរាប់អ្នកទោស ជាពិសេស គឺអ្នកទោសដែលទទួលរងរបួស។

ជាតថភាព អ្នកទោសណាដែលមានលុយ និងក្រុមគ្រួសារមកសួរសុខទុក្ខ គឺអាចជៀសផុតពីការស្រេកឃ្លានប្រចាំថ្ងៃ។ ឬ ឯសំណួក គឺមិនមាននោះទេ ក៏ប៉ុន្តែមានអ្នកទោសខ្លះបានឱ្យប្រាក់ខ្លះៗដែលពួកគេមាន ដើម្បីប្តូរជាមួយនិងម្ហូបអាហារ ដែលពួកគេត្រូវការផ្គត់ផ្គង់ជីវិត។ ផ្អែកទៅលើនីតិវិធីពន្ធនាគារលេខ៦ (មាត្រា ៤ ១)

នាយកពន្ធនាគារត្រូវធានាថា អ្នកទោសគ្រប់រូបទទួលបានម្ហូបអាហារពីរពេលក្នុងមួយថ្ងៃ ដោយមានបរិមាណដូចខាងក្រោម:

| ម្ហូបអាហារតម្រូវការប្រចាំថ្ងៃសំរាប់អ្នកទោស | |
|---|---|
| **ប្រភេទ** | **ចំនួន** |
| អង្ករ | ៥៥០ក្រាម |
| ត្រីស្រស់ ឬ ត្រីងៀត ឬ សាច់ស្រស់ | ១៥០ក្រាម |
| បន្លែ | ១៥០ក្រាម |
| ប្រេងឆា | ១០មីលីលីត្រ |
| អំបិល ឬ ទឹកត្រី | ១០ក្រាម |
| គ្រឿងផ្សំ | ២០ក្រាម |

ទោះបីជាយ៉ាងណាក្តី គឺមិនអាចធ្វើទៅបានឡើយ។ តម្លៃទំនិញនៅទីផ្សារបច្ចុប្បន្ននៅទីក្រុងភ្នំពេញ យ៉ាងហោចណាស់ត្រូវចំណាយប្រាក់អស់១.៧០០រៀល ដើម្បីទិញម្ហូបអាហារប្រចាំថ្ងៃ ឬក៏គ្រឿងផ្សំដែលមានគុណភាពទាបបំផុត។ របបចាស់នៅក្នុងពន្ធនាគារ គឺក្នុងមួយថ្ងៃអ្នកទោសម្នាក់ទទួលបានប្រាក់១.០០០រៀល (០,២៥ ដុល្លារ) ដែលកំណត់ឡើង ដោយរដ្ឋាភិបាលអស់រយៈកាលមួយទសវត្សរ៍ ហើយនៅក្នុងខែសីហា ឆ្នាំ២០០៦ ប្រាក់ឡើងដល់ ១.៥០០រៀល។ អន្តរជាតិបានទទួលស្គាល់ថា ភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា គឺរកប្រាក់ចំណូលបាន ១.៨២៦ រៀល សំរាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ហើយចំណាយទៅលើអាហារប្រហែលជា ១.៤៦០រៀល (៨០%)[៤]។



ទិវាសិទ្ធិនារីឆ្នាំ២០០៦ នៅមណ្ឌលអប់រំកែប្រែ ទី២ "ម-២"

## តើអង្គការលីកាដូកំពុងបំរើសេវាធ្វើអ្វីខ្លះ?

កម្មវិធីពន្ធនាគាររបស់អង្គការលីកាដូ ផ្តល់ម្ហូបអាហារ បន្ថែម និង សំភារៈដល់ពន្ធនាគារ នៅពេលដែលមានឱកាសពិសេស គឺនៅថ្ងៃបុណ្យអន្តរជាតិ (ទិវាសិទ្ធិកុមារថ្ងៃទី១ មិថុនា និងទិវាសិទ្ធិនារីអន្តរជាតិថ្ងៃទី៨ មិនា) និងក្នុងតំរូវការទាន់ណាមួយ។ ម្ហូបអាហារ និង សំភារៈរួមមាន

[៤] ធានាគារពិភពលោក។ ជាញឹកញាប់សួរសំណួរអំពីភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។ http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/CAMBODIAEXTN/0,,contentMDK:20720197~pagePK:141137~piPK:141127~theSitePK:293856,00.html

មុង ធុងទឹក ទឹកដោះគោ អង្ករ គ្រឿងផ្សំ ស្ករស បន្លែ ត្រីងៀត និង អំបិល។

កម្មវិធីពន្ធនាគាររបស់អង្គការលីកាដូ ផ្តល់ម្ហូបអាហារបន្ថែម និង សំភារៈដល់ពន្ធនាគារខេត្តកំពង់ធំ នៅក្នុងកំឡុងឆ្នាំ២០០៥ រហូតដល់ខែកញ្ញា ឆ្នាំ២០០៦។ មកទល់បច្ចុប្បន្ននេះ កម្មវិធីរបស់ខ្លួននៅតែបន្តផ្តល់ម្ហូបអាហារបន្ថែម និង សំភារៈដល់អ្នកទោសនៅមណ្ឌលអប់រំកែប្រែទី៣ "ម-៣"។ ម្ហូបអាហារ និង សំភារៈត្រូវបានផ្តល់ឱ្យអ្នកទោសរៀងរាល់បីខែម្តង អាស្រ័យទៅលើថវិការ។ មណ្ឌលអប់រំកែប្រែទី៣ "ម-៣"ស្ថិតនៅតំបន់ដាច់ស្រយាលជាប់ព្រំប្រទល់កម្ពុជា-វៀតណាម ឃុំត្រពាំងថ្លុង ស្រុកពញាក្រែក ខេត្តកំពង់ចាម។ អ្នកទោសជាច្រើននាក់ ដែលត្រូវបានឃុំខ្លួននៅទីនោះ គឺមកពីខេត្តផ្សេងៗពីគ្នា ដូច្នេះពុំសូវមានមិត្តភក្តិ ឬ ក្រុមគ្រួសារមកសួរសុខទុក្ខ ឬ ផ្តល់អាហារបន្ថែមឱ្យឡើយ។


កម្មវិធីចែកម្ហូបអាហារបន្ថែមដល់មណ្ឌលអប់រំកែប្រែ ទី៣ "ម-៣" ខែមិនា

# ៤. តម្លៃចូលសួរសុខទុក្ខ

### ករណីសិក្សា ទី៣: ការមកសួរសុខទុក្ខនៅពន្ធនាគារ

*នៅក្នុងពន្ធនាគារ យើងស្ទើរតែគ្មានទំនាក់ទំនងជាមួយនឹងអ្នកខាងក្រៅ ក្រៅតែពីជួបជាមួយ និងសាច់ញាតិរបស់យើង ដែលពួកគេត្រូវបង់ប្រាក់ដើម្បីជួបយើង។ នៅក្នុងពន្ធនាគារ យើងអាចធ្វើអ្វីមួយតិចតួចប៉ុណ្ណោះសំរាប់ផ្តល់ឱ្យខ្លួនយើង ដូច្នេះការដែលមានញាតិសន្តានមកសួរសុខទុក្ខ ដោយនាំមកជាមួយនូវសំភារៈផ្សេងៗដល់យើង គឺពិតជាមានសារៈសំខាន់ណាស់។ យើងមិនមែនត្រូវការតែប្រាក់ ឬ ក៏ម្ហូបអាហារប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវការវត្ថុផ្សេងៗទៀត ដូចជា សាប៊ូដុំ ឱសថ ឬ សំលៀកបំពាក់។ ពិតមែនហើយ ការជួបជាមួយក្រុមគ្រួសារ គឺមានសារៈសំខាន់ពីព្រោះធ្វើឱ្យយើងសប្បាយចិត្ត ដោយយើងដឹងថានៅមានមនុស្សយកចិត្តទុកដាក់លើពួកយើង។ វារឹតតែជាការប្រសើរជាងនេះទៅទៀត ប្រសិនបើពួកយើងបានជួបជាមួយមេធាវី។ ពួកយើងត្រូវបានចាក់សោឃុំឃាំង ដោយពុំបានដឹងពីហេតុផលថាតើមានអ្វីកំពុងកើតមានឡើងនៅពិភពខាងក្រៅ។ នៅទីនេះ ខ្ញុំស្គាល់ពិរុទ្ធជនជាច្រើននាក់ ដែលពួកគេកំពុងរង់ចាំថ្ងៃកាត់ទោសពីតុលាការ ហេតុនេះពិតជាមានសារៈសំខាន់ ប្រសិនបើពួកគេមានមេធាវី ឬ បានជួបជាមួយមេធាវី។*

*ជាធម្មតាថ្ងៃទៅសួរសុខទុក្ខ គឺថ្ងៃព្រហស្បតិ៍ ទោះបីជាយ៉ាងណាក៏ដោយ អ្នកអាចទៅសួរសុខទុក្ខនៅកំឡុងថ្ងៃធ្វើការផ្សេងទៀតបាន ប្រសិនបើអ្នកបង់ប្រាក់ឱ្យច្រើន។ រាល់ថ្ងៃចុងសប្តាហ៍ ឬ ថ្ងៃឈប់សំរាកការងារ ពន្ធនាគារមិនអនុញ្ញាតឱ្យភ្ញៀវចូលទេ។ ជានិច្ចជាកាលមិនមែនជាការងាយស្រួលទេ ក្នុងការទៅសួរសុខទុក្ខអ្នកទោស។ អ្នកត្រូវមានអត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណបោះឆ្នោត។ ប្រសិនបើអ្នកគ្មានប័ណ្ណទាំងនោះ អ្នកត្រូវមានលិខិតដែលចុះហត្ថលេខាដោយចៅសង្កាត់ ឬ នាយប៉ូលីសសង្កាត់។ ប្រសិនបើអ្នកត្រូវគេពិន័យដោយបានធ្វើកំហុសអ្វីមួយនៅខាងក្នុងពន្ធនាគារ ឆ្មាំពន្ធនាគារមិនអនុញ្ញាតឱ្យភ្ញៀវសួរសុខទុក្ខអ្នកទេ។ អ្នកទោសនៅទីនេះខ្លះជាប់ពាក់ព័ន្ធទៅនឹងរឿងនយោបាយ ហើយពួកគេមានបញ្ហាក្នុងការជួបជាមួយភ្ញៀវ ជាពិសេស គឺនៅពេលដែលបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចង់មកសួរសុខទុក្ខពួកគេ។*

*ចំណែកឯអ្នកទោសដែលមានសំណាងបានជួបភ្ញៀវមកសួរសុខទុក្ខ គឺត្រូវចំណាយប្រាក់។ អ្នកអាចជួបជាមួយអ្នកទោសនៅខាងមុខបង្អួច ដែលខណ្ឌដោយកញ្ចក់ត្រូវចំណាយប្រាក់ (២.000រៀល = ៥0សេន) ឬ របាំងដែក (១៥,000រៀល = ៣,៧៥ បីដុល្លារចិតសិបប្រាំសេន) ឬ ជួបទល់មុខគ្នា*

*(៤០.០០០រៀល = ១០ដុល្លារ)។ ប្រាកដណាស់តម្លៃ គឺមិនជាក់លាក់ទេ ដូច្នេះពួកគេជានិច្ចជាកាលធ្វើការផ្លាស់ប្តូរស្រេចទៅលើឆ្មាំពន្ធនាគារ។ ខ្ញុំបានព្ត័មានថា នៅពេលដែលមានអ្នកទោសថ្មីចូលមក ឆ្មាំគុកអាចទារថ្លៃចាប់ ពី ៨០.០០០រៀល (២០ដុល្លារ) ដល់ ២០០.០០០រៀល (៥០ដុល្លារ )សំរាប់ការមកសួរសុខទុក្ខម្តង។ ពួកគេនិយាយថា ក្រុមគ្រួសាររបស់អ្នកទោសថ្មី គឺតែងតែមានបំណងចង់បង់ប្រាក់។ ពេលខ្លះភ្ញៀវបានផ្តល់ម្ហូបអាហារ និង អំណោយជាច្រើនដល់អ្នកទោស ហើយអំណោយទាំងនោះត្រូវដកយកខ្លះដោយឆ្មាំពន្ធនាគារ។ ពេលខ្លះ អ្នកទោសចែករំលែកម្ហូបអាហារ និង សំភារៈខ្លះដល់ឆ្មាំពន្ធនាគារ និង អ្នកទោសដទៃទៀត។ នៅក្នុងពន្ធនាគារអ្នកដឹងថា វាពិតជាពិបាកក្នុងការមានរបស់ជាកម្មសិទ្ធផ្ទាល់ ឬការចែករំលែកធ្វើឱ្យជីវិតមានភាពងាយស្រួល។ នៅក្នុងពន្ធនាគារ គឺមិនមានទូរស័ព្ទប្រើនោះទេ។ គឺយើងប្រើទូរស័ព្ទចល័តរបស់ឆ្មាំគុក ដោយបង់ថ្លៃឱ្យពួកគេទ្វេជាពីរនៃតម្លៃធម្មតា។ ពេលខ្លះនេះគឺជាមធ្យោបាយតែមួយគត់ ដែលយើងអាចទាក់ទងមកពិភពខាងក្រៅ។ ប្រសិនបើ អ្នកត្រូវការទាក់ទងមកគ្រួសាររបស់អ្នក ឬ ក៏មេធាវី នេះគឺជាមធ្យោបាយដែលអ្នកអាចធ្វើបាន។ ពេលខ្លះ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក៏អាចជួយរត់សំបុត្រ ឬ ផ្ញើសំបុត្រជំនួសអ្នកផងដែរ។*

*ខ្ញុំគិតថា ដោយសារតែការចូលសួរសុខទុក្ខមានតម្លៃថ្លៃ ដោយរួមទាំងថ្លៃធ្វើដំណើរទៅមកពន្ធនាគារ ហើយតម្លៃនោះ គឺគ្រាន់តែបានចូលខាងក្នុងពន្ធនាគារប៉ុណ្ណោះ។ ក្រុមសាច់ញាតិរបស់អ្នកទោសមកសួរសុខទុក្ខពួកគេក្នុងមួយខែម្តង ឬ ពីរខែម្តងប៉ុណ្ណោះ អាស្រ័យនៅពេលណាដែលពួករកប្រាក់បានដើម្បីបង់ថ្លៃចូលសួរសុខទុក្ខ។ ប្រសិនបើ អ្នកពុំមានប្រាក់ ឬ សាច់ញាតិដែលមានប្រាក់ អ្នកនឹងយល់ថាវាពិតជាពិបាកក្នុងការទំនាក់ទំនងមកកាន់ពិភពខាងក្រៅ។*

## នីតិវិធីពន្ធនាគារ និង ភ្ញៀវ

យោងតាមនីតិវិធីពន្ធនាគារលេខ៨ មាត្រា៤.១ "គ្រប់រូបភាពនៃការប្រមូលយកសំភារៈ ឬ ប្រាក់ពីភ្ញៀវដែលមកសាកសួរសុខទុក្ខអ្នកទោស ដែលប្រព្រឹត្តដោយមន្ត្រីពន្ធនាគារ គឺត្រូវបានហាមឃាត់ដាច់ខាត" នឹងរួមមាន "អ្នកទោសមានសិទ្ធិទទួលបាននូវការមកសួរសុខទុក្ខពីក្រុមគ្រួសារ មិត្តភក្តិយ៉ាងហោចណាស់រយៈពេលមួយម៉ោងរៀងរាល់សប្តាហ៍ នេះជាវិន័យនៅក្នុងពន្ធនាគារដែលកំណត់ដោយប្រធានពន្ធនាគារ[៥]"។ ក៏ប៉ុន្តែវិន័យទាំងនេះ ត្រូវបានគេព្រងើយកន្តើយទាំងស្រុង។ អំពើពុករលួយកាន់តែរាលដាលនៅក្នុងពន្ធនាគារ។ នៅក្នុងរបាយការណ៍ឆ្នាំមុន លីកាដូបានចងក្រងឯកសារអំពីរបៀបប្រមូលយកលុយរបស់ឆ្មាំពន្ធនាគារ ដែលមានជាច្រើនចំណុចនៅពេលដែល

[៥] និតិវិធីពន្ធនាគារលេខ ៨.៣ (១) (ក)

ភ្ញៀវចូលទៅក្នុងពន្ធនាគារ។ គួរពិចារណាថា អ្នកទោសជាច្រើន គឺសុទ្ធតែចេញមកពីគ្រួសារក្រីក្រ ហើយអំពើពុករលួយនេះ គឺបានបង្អាក់ទឹកចិត្តយ៉ាងខ្លាំងដល់សាច់ញាតិអ្នកទោសក្នុងការមកសួរសុខទុក្ខពួកគេ។

## តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ?

ជាញឹកញាប់អង្គការលីកាដូត្រូវបានគេបដិសេធមិនឱ្យចូលទៅក្នុងពន្ធនាគារ ដើម្បីជួបជាមួយអ្នកទោសដែលខ្លួនចង់ជួប ទោះបីជាយ៉ាងនេះក៏ដោយ យើងនៅរក្សាគោលនយោបាយយ៉ាងម៉ឺងម៉ាត់ ក្នុងការមិនផ្តល់ជាសំណូក នឹងបង់ថ្លៃចូលសួរសុខទុក្ខដល់ពន្ធនាគារ។ ពិរុទ្ធជនសំខាន់ៗ ឬ អ្នកទោសនយោបាយ ឬ អ្នកទោសងាយរងគ្រោះ គឺយល់ថា វាមានការពិបាកក្នុងការទទួលបានការមកសួរសុខទុក្ខពីភ្ញៀវ ហេតុនេះអង្គការលីកាដូ បានជូនមិត្តភក្តិ និង សមាជិកក្រុមគ្រួសាររបស់ពួកគេឱ្យបានចូលជួបដល់ខាងក្នុងពន្ធនាគារ។ នៅក្នុងឆ្នាំ២០០៦ អ្នកស្រាវជ្រាវពន្ធនាគារលីកាដូ បានជូនសមាជិកក្រុមគ្រួសារចំនួន ១៥នាក់របស់អ្នកទោស ដើម្បីទៅសួរសុខទុក្ខនៅក្នុងពន្ធនាគារដែលរួមមានដូចខាងក្រោម។

- ជូនម្តាយទៅសួរសុខទុក្ខកូនប្រុសរបស់គាត់ដែលត្រូវបានចោទប្រកាន់ពីបទផ្តល់ព័ត៌ក្លែងក្លាយ បន្ទាប់ពីគាត់បានរិះគន់លើរដ្ឋាភិបាល។
- ជូនកុមារអាយុ៤ឆ្នាំទៅសួរសុខទុក្ខម្តាយនៅមណ្ឌលអប់រំកែប្រែទី២ "ម-២"។
- ជូនបុរសម្នាក់ទៅសួរសុខទុក្ខប្អូនប្រុសរបស់គាត់នៅមណ្ឌលអប់រំកែប្រែទី១ "ម-១" ដែលត្រូវបានចោទប្រកាន់ពីបទធ្វើភេរវកម្ម។
- ជូនស្ត្រីម្នាក់ទៅសួរសុខទុក្ខប្តីរបស់គាត់ ដែលត្រូវបានចោទប្រកាន់ពីបទជួញដូរមនុស្ស។



ប្រពន្ធអ្នកជាប់ឃុំឃាំង (រួមជាមួយបុគ្គលិកអង្គការ) នៅខាងក្រៅបរិវេណមណ្ឌលអប់រំកែប្រែទី១ "ម-១" ឈរកាន់អាវយឺតពណ៌លឿង ដើម្បីគាំទ្រប្តីរបស់ពួកគេ បន្ទាប់ពីអាជ្ញាធរមិនបានអនុញ្ញាត អោយពួកគាត់ប្រគល់អាវយឺតដល់ប្តីរបស់ពួកគេនៅខាងក្នុងពន្ធនាគារ។

# ៥. ពេលវេលាកន្លង

**ករណីសិក្សា ទី៤ : ការធ្វើលំហាត់ប្រាណនៅក្នុងពន្ធនាគារ**

*កណ្តឹងរោទិ៍នៅម៉ោង ៤ពេលព្រឹកព្រលឹម គឺជាការរំឭកខ្ញុំថា វាដល់ថ្ងៃចាប់ផ្តើមនៃថ្ងៃមួយទៀត ហើយសម្រាប់ឆាកជីវិតរស់នៅក្នុងពន្ធនាគារ...*

*កណ្តឹងរោទិ៍ដាស់យើងរាល់គ្នាឱ្យក្រោកនៅម៉ោង៤ជារៀងរាល់ព្រឹក ហើយពួកគេក៏បានបិទភ្លើង។ វាជាពេលព្រលឹមអុរ ហើយមានពន្លឺព្រះអាទិត្យតែបន្តិចបន្តួចប៉ុណ្ណោះ។ យើងគ្មានកិច្ចការអ្វីដែលត្រូវធ្វើច្រើនទេនៅក្នុងពន្ធនាគារ ដោយគ្រាន់តែអង្គុយនៅក្នុងបន្ទប់ឃុំឃាំងដែលមានក្លិនស្អុះឈ្លួល។ យើងមិនបានទទួលម្ហូបអាហាររហូតរយៈពេល៦ម៉ោង។ ខ្ញុំមានចម្ងល់ថា ហេតុអ្វីបានជាពួកយើងត្រូវក្រោកពីព្រលឹមយ៉ាងដូច្នេះ វាហាក់ដូចជាមិនមានអ្វីដែលយើងត្រូវធ្វើនោះទេ។ ក្នុងមួយសប្តាហ៍ ខ្ញុំ និង អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងត្រូវបានគេអនុញ្ញាតឱ្យចេញហាត់ប្រាណនៅខាងក្រៅបន្ទប់ម្តង។ នៅថ្ងៃនោះ យើងត្រូវបានអនុញ្ញាតឱ្យចេញមកខាងក្រៅនៅពេលព្រឹក និង ពេលរសៀល ប៉ុន្តែបានត្រឹមតែរយៈពេល ១ម៉ោងទៅ ២ម៉ោងប៉ុណ្ណោះ។ យើងត្រូវបានគេរាប់ទាំងពេលចេញមកក្រៅ និង ពេលត្រលប់ចូលខាងក្នុងវិញ។ តើរយៈពេលប៉ុន្មាន ដែលអ្នកទោសត្រូវបានគេអនុញ្ញាតឱ្យបន្តរកាយនោះ គឺអាស្រ័យលើឆ្មាំពន្ធនាគារ ប្រសិនបើ ពួកគេមានអារម្មណ៍ល្អ។ ខ្ញុំបានដឹងថា អ្នកអាចចេញមកហាត់ប្រាណជារៀងរាល់ថ្ងៃដោយបង់ប្រាក់ឱ្យឆ្មាំពន្ធនាគារ។ វាពិតជាការប្រសើណាស់ ប្រសិនបើខ្ញុំមានប្រាក់។*

*ក្នុងកំឡុងពេលធ្វើលំហាត់ប្រាណ មានចំនួនអ្នកទោសចេញពី៤ ទៅ ៥បន្ទប់ឃុំឃាំងត្រូវបានអនុញ្ញាតឱ្យចេញមកខាងក្រៅ។ ដោយសារតែបរិវេណពន្ធនាគារធំ ពួកគេត្រូវតែកំណត់ចំនួនអ្នកទោសនឹងឱ្យពួកគេដើរជុំវិញ និង ម្យ៉ាងវិញទៀតដោយសារពុំមានអ្នកយាមគ្រប់គ្រាន់ ដើម្បីមើលពួកគេ។ យើងធ្លាប់បានចេញមកខាងក្រៅឃើញពន្លឺព្រះអាទិត្យ ហើយយើងមិនអាចធ្វើអ្វីបានច្រើនឡើយ។ ពួកយើងត្រូវបានអនុញ្ញាតឱ្យដើរជុំវិញទីធ្លាពន្ធនាគារ ដែលនៅក្បែរបន្ទប់ឃុំឃាំងតែប៉ុណ្ណោះ។ យើងពុំមានសំភារៈដើម្បីប្រើប្រាស់ទេ ដូច្នេះពេលវេលាភាគច្រើន គឺយើងដើរជុំវិញ រីឯអ្នកខ្លះធ្វើលំហាត់ប្រាណពត់ដៃ-ជើង។ ចំពោះអ្នកទោសណា ដែលមានម្ហូបអាហារ ក៏អាចយកមកចំអិននៅខាងក្រៅផងដែរ។ ចំណែកឯអ្នកទោសខ្លះទៀតលាងសំអាតខ្លួន ឬ ក៏បោកសំលៀកបំពាក់នៅខាងក្រៅ។ ពិតប្រាកដណាស់ នៅខាងក្រៅបន្ទប់ឃុំឃាំងមានបរិយាកាសល្អជាងនៅក្នុងបន្ទប់ឃុំឃាំងដែលមានតែក្លិនស្អុះស្អាប។ បរិយាកាសបែបនេះ គឺជាអ្វីដែលខ្ញុំចង់បាន។ នៅពេលដែលពុំមានថ្ងៃធ្វើលំហាត់ប្រាណ គឺយើងត្រូវអង្គុយនៅក្នុងបន្ទប់ឃុំឃាំង។*

ពួកយើងអង្គុយជជែកជាមួយ និងអ្នកទោសដូចគ្នា ហើយអ្នកខ្លះក៏ដេក។ ពេលវេលាភាគច្រើនរបស់យើងគឺមិនបានធ្វើអ្វីទាល់តែសោះ។ អ្នកទោសដែលជាអ្នកមានលុយខ្លះ ចំណាយពេលវេលាប្រើគ្រឿងញៀនដូចជា ប្រភេទយ៉ាម៉ា ដែលពួកគេទទួលបានពីក្រុមគ្រួសារ ឬ ទិញពីឆ្មាំពន្ធនាគារ។ ពួកគេពុំអនុញ្ញាតឱ្យយើងមានវិទ្យុ កាសែត ឬ ទូរទស្សន៍ទេ។ ពេលខ្លះក៏មានអ្នកទោសលួចយកវិទ្យុចូលទៅក្នុងបន្ទប់ឃុំឃាំងដែរ ប៉ុន្តែ ប្រសិនបើមេក្រុមនៅក្នុងបន្ទប់ឃុំឃាំង ឬ ឆ្មាំពន្ធនាគារដឹង ពួកគេនឹងដកហូត ព្រមទាំងដាក់ទណ្ឌកម្មមកលើអ្នកទោសនោះទៀតផង។

ផ្ទៃដីមួយផ្នែកតូចនៅក្នុងពន្ធនាគារ ត្រូវបានគេប្រើសំរាប់ដាំបន្លែដើម្បីយកធ្វើម្ហូប ហើយមានអ្នកខ្លះត្រូវបានគេប្រើឱ្យជួយដាំបន្លែ នឹងដាក់បាយជ្រូក។ អ្នកនឹងមានសំណាង ប្រសិនបើឆ្មាំគុកជ្រើសរើសអ្នកឱ្យជួយធ្វើកិច្ចការនេះ ពីព្រោះអ្នកអាចចេញមកខាងក្រៅបន្ទប់ឃុំឃាំងជារៀងរាល់ថ្ងៃ។ ដូច្នេះអ្នកមានឱកាសក្នុងការចំអិនម្ហូបរបស់អ្នក ប្រសិនបើអ្នកមាន។ ខ្ញុំបានដឹងថា ដំណាំ និង សត្វជ្រូកដែលចិញ្ចឹម គឺមិនមែនសំរាប់អ្នកទោសទេ។ ពន្ធនាគារទិញផលដំណាំ និង ជ្រូកនៅពេលល្មមលក់ ហើយពួកគេយកវាទៅលក់បន្តនៅឯផ្សារ ហើយយកលុយទាំងនោះ។

នៅវេលាម៉ោង៦ល្ងាច ភ្លើងនៅជុំវិញពន្ធនាគារចាប់ផ្តើមបើកបំភ្លឺ ហើយនៅវេលាម៉ោង១០យប់ ភ្លើងនៅក្នុងបន្ទប់ឃុំឃាំងរបស់យើងត្រូវបានបិទ ដែលជាសញ្ញាថា គឺដល់ពេលនៃការបញ្ចប់ថ្ងៃរបស់ពួកយើង។ អ្នកទោសខ្លះមានទៀន ឬ ចង្កៀង បានប្រើវាដុតបំភ្លឺនៅពេលដែលភ្លើងអគ្គិសនីត្រូវបានពន្លត់។ ខ្ញុំផ្លាស់ទីកន្លែងដេករបស់ខ្ញុំស្ទើតែរៀងរាល់ថ្ងៃ។

## បទដ្ឋានអប្បបរិមារនៃអង្គការសហប្រជាជាតិស្តីពីការធ្វើលំហាត់ប្រាណ

គ្រប់អ្នកទោសទាំងអស់ គឺមានសិទ្ធិចេញធ្វើលំហាត់ប្រាណ។ យោងទៅតាមច្បាប់បទដ្ឋានអប្បបរិមាររបស់អង្គការសហប្រជាជាតិក្នុងមាត្រា ២១ (១) សំរាប់ការប្រព្រឹត្តិទៅលើអ្នកទោសគឺ "រាល់អ្នកទោសណា ដែលមិនត្រូវបានគេប្រើឱ្យទៅធ្វើការនៅខាងក្រៅ គឺមានពេលយ៉ាងហោចណាស់ ១ម៉ោង ដើម្បីធ្វើលំហាត់ប្រាណនៅកន្លែងដែលមានខ្យល់អាកាសល្អជារៀងរាល់ថ្ងៃ ប្រសិនបើអាកាសធាតុអំណោយផល[៦]។" ជាការពិត អ្នកទោសណាដែលឃុំក្នុងបន្ទប់មានចំនួនអ្នកទោសចង្អៀតណែន គឺមានឱកាសបានសំរាកបន្ធូរកាយតែម្តងប៉ុណ្ណោះក្នុងមួយសប្តាហ៍។ ដោយឡែក បន្ទប់ឃុំឃាំងដែលមានអ្នកទោសតិច គឺអាចសំរាកលំហែកាយបានច្រើនដង រីឯអ្នកទោស ដែលមានលទ្ធភាពសូកសំណូក គឺអាចចេញមកខាងក្រៅហាត់ប្រាណជារៀងរាល់ថ្ងៃ។

## ឪយ៉ាក្រាមពន្ធនាគារ

ទ្រង់ទ្រាយឪយ៉ាក្រាមពន្ធនាគារខេត្តកំពង់ធំ







ខាងលើគឺជាឪយ៉ាក្រាមរបស់ពន្ធនាគាខេត្តកំពង់ធំ។ អគារលេខ១ គឺជាអគារបណ្តោះអាសន្ន ដែលមានរបាំងដែក កំរាលឥដ្ឋចាក់បេតុង ហើយដំបូលប្រក់ដោយផ្ទាំងក្រណាត់កៅស៊ូ។ ចំណែកឯអគារទី២ មានជញ្ជាំងចាក់បេតុង

[៦] ច្បាប់បទដ្ឋានអប្បបរិមារសំរាប់ការប្រព្រឹត្តលើអ្នកទោស [ច្បាប់នេះគឺសំរាប់ប្រព្រឹត្តទៅលើអ្នកទោស]។ច្បាប់នេះត្រូវបានអនុម័ត ដោយសមាជទីមួយរបស់អង្គការសហ ប្រជាជាតិស្តីអំពីកិច្ចការពារបទល្មើស និងការប្រព្រឹត្តទៅលើអ្នកទោស ដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងស៊ឺណែវក្នុងឆ្នាំ១៩៥៥ យល់ព្រមដោយក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចតាមសេចក្តីសម្រេចលេខ៦៦៣ (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៥៧ និងលេខ២០៧៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧។ ច្បាប់នេះមិនបានភ្ជាប់កតព្វកិច្ចអោយប្រើតាមច្បាប់នៅក្នុងប្រទេសកម្ពុជាទេ ក៏ប៉ុន្តែច្បាប់នេះ គឺជាកម្លាំងសិលធម៌ដែលមិនអាចបដិសេធបាន និងផ្តល់ជាមូលដ្ឋានគ្រឹះគំរូសំរាប់ប្រទេសដ៏ទៃៗ ទៀតដែលពុំមានច្បាប់ នេះប្រើនៅក្នុងប្រទេស។

ដែល ប្រក់ដំបូលយ៉ាងមាំ ហើយមានបង្អួចតូចនៅក្បែរនឹងពិដាន។ អគារនិមួយៗ គឺមានទំហំ ៧.៥ ម៉ែត្រ គុណនឹង ១៥ ម៉ែត្រ ដែលមានបន្ទប់ឃុំឃាំងដូចៗគ្នា។ អ្នកទោសដេកនៅលើកន្ទេលផ្ទាល់នឹងកំរាលឥដ្ឋតាមបណ្តោយអគារ។

នៅក្នុងខែតុលា ឆ្នាំ២០០៦ អគារទាំងពីររបស់អ្នកទោសបុរសផ្ទុកអ្នកទោសចំនួន ១១៥នាក់ បូកបញ្ចូលអនីតិជន ៥នាក់ ហើយអគារសំរាប់អ្នកទោសស្ត្រីមានអ្នកទោស ១១នាក់។ ប៉មយាម៤កន្លែងរបស់អ្នកយាម និងទីជម្រកភ្លៀងតូចមួយរបស់ពួកគេ ស្ថិតនៅលើជញ្ជាំងនៃបរិវេណពន្ធនាគារ។ ខេត្តកំពង់ធំ គឺជាពន្ធនាគារមួយដែលមានឈ្មោះខាងរឿងអាស្រូវបំផុតនៅក្នុងចំណោមពន្ធនាគារនានាក្នុងប្រទេសកម្ពុជា។ ពន្ធនាគារនេះ ត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩០៥ ដោយជនជាតិបារាំង ហើយអស់រយៈពេលជាច្រើនឆ្នាំកន្លងមកវានៅតែតូចចង្អៀត។ នៅខែមករា ឆ្នាំ២០០៦ ពន្ធនាគារមានអ្នកទោសយ៉ាងច្រើនតាន់តាប់ ដូច្នេះ ដើម្បីសម្រួលនូវភាពតានតឹងនេះ នាយកពន្ធនាគារបានបង្ខំចិត្តអនុញ្ញាតឱ្យអ្នកទោសមួយចំនួនដេកនៅខាងក្រៅបន្ទប់ឃុំឃាំង ដែលអាចបង្កឱ្យមានបញ្ហាសន្តិសុខ។ ប៉ុន្មានខែបន្ទាប់មក អ្នកទោសចំនួន ១៧នាក់ត្រូវបានបញ្ជូនមកមណ្ឌលអប់រំកែប្រែទី១ "ម-១" និងអ្នកទោស ១០នាក់ផ្សេងទៀតមកមណ្ឌលអប់រំកែប្រែទី៣ "ម-៣"[៧]។

**ទ្រង់ទ្រាយឪយ៉ាក្រាមមណ្ឌលអប់រំកែប្រែទី២ "ម-២" នៅភ្នំពេញសំរាប់អ្នកទោសស្ត្រី និង អនីតិជន**











ឱយ៉ាក្រាមខាងលើ គឺជាទ្រង់ទ្រាយរបស់មណ្ឌលអប់រំកែប្រែទី២ "ម-២"។ គ្រប់អគារទាំងអស់ត្រូវបានចាក់បេតុងយ៉ាងរឹងមាំ ហើយមានបង្អួចតូចៗជាច្រើន។ មានបន្ទប់ឃុំឃាំង៤ធំៗសំរាប់អ្នកទោសស្ត្រី ហើយបន្ទប់និមួយៗដាក់អ្នកទោសប្រហែលជា ៦០នាក់។ ចំណែកឯអ្នកទោសជាអនីតិជន មានបន្ទប់ឃុំឃាំងតូចចំនួន ៦ ដែលមានអ្នកទោសប្រហែលជា ៣០នាក់ ហើយបន្ទប់ធំពីរផ្សេងទៀត មានអ្នកទោសចំនួន ៦០នាក់ជាអនីតិជន។ នៅក្នុងខែតុលា ឆ្នាំ២០០៦ មណ្ឌលអប់រំកែប្រែទី២ "ម-២" បានផ្ទុកអ្នកទោសស្ត្រីសរុបមានចំនួន ២៥៦នាក់អ្នកទោសជាអនីតិជនមានចំនួន ២៨៥នាក់ រួមទាំងក្មេង ១៤នាក់ និង ទារកដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ។

មុនឆ្នាំ១៩៩៩ មណ្ឌលអប់រំកែប្រែទី២ "ម-២" ត្រូវបានគេហៅថាតេពីរ (T2) គឺជាពន្ធនាគារសំរាប់ដាក់អ្នកទោសបុរស អ្នកទោសស្ត្រី និង អ្នកទោសជាអនីតិជន ដែលមានទីតាំងស្ថិតនៅជាយទីក្រុងភ្នំពេញ។ អ្នកទោសភាគច្រើនត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារក្នុងទីក្រុងភ្នំពេញ ដែលហៅថាតេបី (T3) ស្ថិតនៅចំកណ្តាលទីក្រុងភ្នំពេញ។ ដីនៅពន្ធនាគារតេបីត្រូវបានលក់ឱ្យក្រុមហ៊ុនឯកជនក្នុងតម្លៃថ្លៃ បន្ទាប់មកពីក្រុមហ៊ុនបានទិញមួយកន្លែងនៅជាប់និងមណ្ឌលអប់រំកែប្រែទី២ "ម-២" ដើម្បីសាងសង់ពន្ធនាគារនៅទីនោះជំនួសវិញ។ គំនិតផ្តួចផ្តើមនៃផែនការនេះ គឺដើម្បីឃុំអ្នកទោសបុរស អ្នកទោសស្ត្រី និង អ្នកទោសជាអនីតិជននៅក្នុងពន្ធនាគារថ្មីនោះទាំងអស់។ តែពេលនោះ ក៏មានការតស៊ូមិត និង ការបញ្ចុះបញ្ចូលពីអង្គការមិនមែនរដ្ឋាភិបាល ស្នើសុំឱ្យរាជរដ្ឋាភិបាលបំបែកអ្នកទោសជំទង់ៗចេញពីអ្នកទោសស្ត្រី និង អ្នកទោសជាអនីតិជន។ បច្ចុប្បន្ននេះ មណ្ឌលអប់រំកែប្រែទី២ "ម-២" ឃុំតែអ្នកទោសស្ត្រី និង អ្នកទោសជាអនីតិជនប៉ុណ្ណោះ។ ចំណែកឯមណ្ឌលអប់រំកែប្រែទី១"ម-១" គឺជាពន្ធនាគារដ៏ធំជាងគេនៅក្នុងប្រទេស ដែលជាកន្លែងឃុំខ្លួនអ្នកទោសបុរស[៧]។

[៧] កាសែតឌឹខេមបូឌាដេលី ចេញផ្សាយថ្ងៃព្រហស្បតិ៍ ទី២៦ ខែមករា ឆ្នាំ២០០៦ លេខ៣៣ លើកទី៥៨

# ៦. នរណាចាំឃ្លាំមើលខ្ញុំ?

## ករណីសិក្សាទី ៥: ឆ្មាំពន្ធនាគារ

*ពួកយើងរស់ក្រោមការមេត្តារបស់ឆ្មាំពន្ធនាគារ នៅទីនោះពួកគេ គឺជាច្បាប់ហើយយើងត្រូវតែធ្វើតាមអ្វីដែលពួកគេនិយាយ។*

*អ្នកពិតជាមិនធ្លាប់ដឹងទេ ថាតើមានឆ្មាំពន្ធនាគារប៉ុន្មាននាក់នៅទីនេះ។ យើងធ្លាប់ឃើញតែពួកគេដើរល្បាតនៅខាងក្រៅបន្ទប់ឃុំឃាំងរបស់យើង ឬ ឈរយាមឃ្លាំមើលមកយើងពីលើប៉ មអគារតែប៉ុណ្ណោះ។ ឆ្មាំពន្ធនាគារតែងតែប្តូរវេនគ្នានៅវេនយប់ និង វេនថ្ងៃ។ ពួកគេកាន់ដំបងឈើ ប៉ុន្តែ អ្នកខ្លះកាន់ដំបងឆក់ និង ខ្លះកាន់កាំភ្លើង។ ខ្ញុំតែងតែរក្សាចំងាយឱ្យឆ្ងាយពីឆ្មាំពន្ធនាគារទាំងនោះ ព្រោះខ្ញុំមិនចង់ត្រូវពួកគេវាយ ព្រោះករណីនេះមានកើតឡើងពេលខ្លះដែរ។*

*ខ្ញុំធ្លាប់បានឮពីមុនមកថាឆ្មាំពន្ធនាគារធ្លាប់ធ្វើទារុណកម្មលើអ្នកទោសរហូតដល់ស្លាប់ នេះមិនមានន័យថាអ្នកទោសទាំងនោះគ្រាន់តែត្រូវគេវាយមួយ ឬ ពីរដំបងនោះទេ ប៉ុន្តែ ការធ្វើទារុណកម្មនេះគឺវាយយ៉ាងធ្ងន់ធ្ងររហូតដល់សន្លប់ ឬ វាយរហូតដល់ថ្នាក់ត្រូវការគ្រូពេទ្យជួយសង្គ្រោះ។ ពេលខ្លះការធ្វើទារុណកម្មប្រព្រឹត្តឡើងក្រោមរូបភាព ដូចជាអ្នកទោសត្រូវដាក់ខ្នោះភ្ជាប់ទៅនឹងបង្គោលក្នុង ឬ ក្រៅបន្ទប់ឃុំឃាំង ប្រហែលជាពីរថ្ងៃដោយមិនអាចកំរើកទៅណារួច។ មានពេលខ្លះទៀតទារុណកម្មធ្វើឡើងដោយសារតែអ្នកទោសប្រព្រឹត្តអ្វីខុស-អាចមកពីមូលហេតុពួកគេវាយតប់គ្នា ឬ គេចាប់បានដោយសារលួចរបស់របរ-ប៉ុន្តែ ខ្ញុំមិនគិតថាវាជាការត្រឹមត្រូវទេ ដែលពួកគេត្រូវបានវាយយ៉ាងធ្ងន់ធ្ងរដូចនេះ។*

*ខ្ញុំមិនធ្លាប់ត្រូវគេធ្វើទារុណកម្មម្តងណាឡើយ ប៉ុន្តែ ខ្ញុំពិតជាមានការភ័យខ្លាចណាស់ ប្រសិនបើរឿងនេះកើតឡើងចំពោះខ្ញុំ។ ខ្ញុំឃើញអ្នកទោសខ្លះត្រូវគេធ្វើទារុណកម្មមើលទៅស្រពាប់ស្រពោន ហាក់បីដូចជាព្រលឹងរបស់ពួកគេបែកខ្ញែកចេញពីខ្លួន។ ប្រសិនបើរឿងនេះកើតឡើងចំពោះខ្ញុំមែន ខ្ញុំពិតជាមិនដឹងថាទៅប្រាប់នរណាម្នាក់ ឬ ខ្ញុំគួរប្រាប់ដែរឬទេ ព្រោះអ្នកអាចត្រូវគេវាយបន្ថែម ប្រសិនបើអ្នកនិយាយរឿងនេះ។ ប៉ុន្តែបើអ្នកមានសំណាងអ្នកអាចនិយាយប្រាប់បុគ្គលិកអង្គការ ប្រសិនបើពួកគេចូលទៅសម្ភាសន៍ អ្នកហើយគ្មានឆ្មាំពន្ធនាគារនៅចាំឃ្លាំមើល ឬ លួចស្តាប់ក្បែរ។ ខ្ញុំជឿជាក់ថាអ្នកមិនអាចគេចផុតពីការឃ្លាំមើលយ៉ាងតឹងរឹងរបស់ឆ្មាំពន្ធនាគារឡើយ ប្រសិនបើពួកគេចង់ធ្វើបាបអ្នក។*

*ប្រធានពន្ធនាគារ គឺជាមេធំជាងគេនៅក្នុងពន្ធនាគារ ហើយគាត់ គឺជាអ្នកបញ្ជាថាតើអ្វីដែលឆ្មាំ*

ពន្ធនាគារត្រូវធ្វើ ប៉ុន្តែ ខ្ញុំគិតថានៅទីបំផុតនោះ គឺឆ្មាំពន្ធនាគារទេ ដែលជាអ្នកធ្វើសេចក្តីសំរេចចុងក្រោយនៅក្នុងពន្ធនាគារ ។ ឆ្មាំពន្ធនាគារទាំងនោះ គឺជាអ្នកដែលយើងចំណាយលុយទៅឱ្យ ដើម្បីទទួលបានអាហារច្រើន ពេលវេលាសំរាកលំហែរច្រើន ហើយពួកគេទាំងនោះក៏ជាអ្នកដែលបងប្អូនសាច់ញាតិរបស់យើងបង់លុយឱ្យ ដើម្បីបានចូលសួរសុខទុក្ខ ។ ឆ្មាំពន្ធនាគារ គឺជាអ្នកដែលធ្វើការសំរេចចិត្តលើអ្វី ដែលអាចធ្វើ ឬមិនអាច ។ ពួកគេ គឺជាអ្នកដែលវាយយើង ឬ បញ្ជាទៅប្រធានបន្ទប់ឃុំឃាំងឱ្យវាយយើង ។ ឆ្មាំពន្ធនាគារអាចបញ្ជូនយើងទៅដាក់ក្នុងបន្ទប់ទណ្ឌកម្មតូច ក្រខ្វក់ និង គ្មានពន្លឺ ។

ខ្ញុំស្គាល់ឆ្មាំពន្ធនាគារខ្លះដែលស្នាក់នៅក្នុងបរិវេណពន្ធនាគារ អ្នកអាចឮសំលេង និងមើលឃើញកូនៗរបស់ពួកគេជានិច្ចជាកាលរត់លេងនៅក្នុងបរិវេណពន្ធនាគារ ។ ខ្ញុំគិតថាការស្នាក់នៅក្នុងពន្ធនាគារមានការងាយស្រួលដោយចំណាយតិច អ្នកមិនចាំបាច់ធ្វើដំណើរឆ្ងាយទៅមកធ្វើការ ហើយអ្នកអាចឃើញនឹងរស់នៅជាមួយក្រុមគ្រួសារបាន ។ ប៉ុន្តែ ខ្ញុំគិតថា ការងារនៅក្នុងពន្ធនាគារមិនមែនជាការងារមានប្រជាប្រិយឡើយ ខ្ញុំឮថាប្រាក់បៀវត្សរ៍នៅទីនេះមិនច្រើនទេ បើចំពោះរូបខ្ញុំវិញ គឺមិនចង់ធ្វើការនៅកន្លែងតានតឹងរបៀបនេះឡើយ ។

ឆ្មាំពន្ធនាគារមានបង្គន់ និង បន្ទប់ទឹកផ្ទាល់ខ្លួនដោយឡែក ហើយពួកគេញ៉ាំអាហារល្អៗ ប៉ុន្តែនៅទីបំផុតពួកគេចំណាយពេលទាំងអស់របស់គេធ្វើការនៅក្នុងកន្លែងដ៏សោកសៅនេះ ដែលពួកយើងហៅកន្លែងនេះថាជាផ្ទះ ។ ពួកយើងរស់នៅក្នុងបរិស្ថានក្រខ្វក់ ហើយពួកគេទាំងនោះក៏ត្រូវតែធ្វើការនៅទីនេះដូចគ្នាដែរ ។ ខ្ញុំគិតថាប្រសិនបើ អ្នកទោសឈឺនោះ ពួកគេក៏អាចនឹងមានជំងឺដូចគ្នាដែរ ។ នៅទីនេះមិនមានគ្រូពេទ្យពិសេស ឬសេវាពេទ្យល្អសំរាប់ឆ្មាំពន្ធនាគារឡើយ ពួកគេក៏ទទួលសេវាពេទ្យពីបុគ្គលិកផ្នែកសុខភាពដូចអ្នកទោសដែរ ហើយនៅពេលខ្លះ ពួកគេប្រើបុគ្គលិកពេទ្យរបស់អង្គការដែលមកសួរសុខទុក្ខអ្នកទោសដូចគ្នា ។ មានពេលខ្លះទៀតខ្ញុំអាចយល់បានថា ហេតុអ្វីបានជាឆ្មាំពន្ធនាគារទាំងនោះចង់បានសំណូក នេះក៏ព្រោះតែពួកគេមានស្ថានភាពជីវភាពក្រីក្រ និង ជីវភាពលំបាកដែរ ។ ខ្ញុំមិនចង់រស់នៅក្នុងនេះឡើយ ប្រសិនបើខ្ញុំមិនមានទោសពៃរ៍នោះ ។

## ឆ្មាំពន្ធនាគារ

ឆ្មាំពន្ធនាគារទទួលបានប្រាក់បៀវត្សរ៍មួយខែ ២០០.០០០ រៀល (៥០ ដុល្លារ) ដែលកាលពីមុនទទួលបានតែ ៩០. ០០០ រៀល (២២,៥០ ដុល្លារ) ក្នុងមួយខែ។ ប្រាក់ខែនេះត្រូវបានដំឡើងក្នុងឆ្នាំ ២០០៤ បន្ទាប់ពីការបោះឆ្នោតជាសកលទូទាំងប្រទេសលើកទី៣ និងជាលទ្ធផលនៃកំណែទំរង់ប្រព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានពន្ធនាគារ។ មានឆ្មាំពន្ធនាគារ និង គ្រួសារជាច្រើនបានមករស់នៅក្នុងបរិវេណពន្ធនាគារ ហើយពួកគេមានកំរិតជីវភាពមិនល្អជាងអ្នកទោសទាំងនោះឡើយ។ ដោយមូលហេតុទាំងនេះ ឆ្មាំពន្ធនាគារមួយចំនួនដែលត្រូវប្រើប្រាស់អ្នកទោសដូចជាឈ្លើយសំរាប់ទីផ្សារមួយសំរាប់រកចំណូលប៉ះប៉ូវបន្ថែមលើប្រាក់បៀវត្សរ៍ដែលពួកគេបានទទួល។

## អំពើទារុណកម្ម

អ្នកទោសត្រូវបានការពារពីអំពើទារុណកម្មតាមអនុសញ្ញាស្ដីពីការប្រឆាំងនឹងអំពើទារុណកម្ម និង អំពើព្រៃផ្សៃ អមនុស្សធម៌ ការបន្ទាបបន្ថោក ឬ ទណ្ឌកម្មនានាដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័ន។ អ្នកទោសត្រូវបានការពារក្រោមមាត្រា ១២ (១) នៃច្បាប់អន្តរកាល (ច្បាប់មួយនៃច្បាប់មូលដ្ឋានរបស់ព្រះរាជាណាចក្រកម្ពុជា) បានចែងថា "គ្មានពិរុទ្ធជនណាត្រូវរងអំពើព្រៃផ្សៃ អមនុស្សធម៌ ការធ្វើបាប ឬ ទណ្ឌកម្ម ក៏ដូចជាការវាយដំ ឬ ទារុណកម្មណាមួយឡើយ។"[៨]


អ្នកទោសត្រូវដាក់ខ្នោះខណៈពេល នៅមន្ទីរពេទ្យ

ច្បាប់អន្តរកាល (មាត្រា ១២) ត្រង់ចំណុចចែងអំពីការប្រព្រឹត្តចំពោះពិរុទ្ធជនបានចែងថា "មិនត្រូវដាក់ខ្នោះអ្នកទោស ឬ ដាក់ក្នុងកន្លែងដាច់ដោយឡែកណាមួយឡើយ ទោះជាស្ថិតក្នុងដំណាក់កាលឃុំឃាំងបណ្ដោះអាសន្ន ឬ កាត់ទោសហើយក៏ដោយ។" នេះមានន័យថាការដាក់ខ្នោះអ្នកទោសជាទម្រង់ដាក់ទណ្ឌកម្មមិនត្រូវប្រើប្រាស់ទេ។ ខ្នោះ គឺជាឧបករណ៍ប្រើសំរាប់ផ្នែកសន្តិសុខ សម្រាប់ដាក់អ្នកទោសកុំឱ្យរត់តែប៉ុណ្ណោះ។

[៨] អនុសញ្ញាស្ដីពីការប្រឆាំងនឹងអំពើទារុណកម្ម និងអំពើព្រៃផ្សៃ អមនុស្សធម៌ ការបន្ទាបបន្ថោក ឬទារុណកម្ម និងការដាក់ទោស។ សេចក្ដីសំរេចមហាសន្និបាតលេខ ៣៦/៤៦ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៨៤, ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រាទី ១២ (១)

នៅក្នុងសេចក្តីប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ (មាត្រា ២៥) ចែងថា "ខ្នោះដៃអាចជាឧបករណ៍តែមួយគត់ដែលត្រូវប្រើ ដើម្បីដាក់អ្នកទោសកុំឱ្យរត់ តែមិនត្រូវប្រើ ដើម្បីជាការដាក់ទោសឡើយ។"[៥] មាត្រានេះក៏បានចែងផងដែរថា "ប្រធានពន្ធនាគារអាចបញ្ជាឱ្យដាក់ខ្នោះក្នុងករណីៈ *ក)* ការទប់ទល់ នឹងការរត់គេច ឬ *ខ)* ប្រសិនបើវិធានការផ្សេងៗមិនអាចទប់ទល់ក្នុងកិច្ចការពារអ្នកទោសពីការបង្ករបួសខ្លួនឯង ឬ អ្នកដទៃ ឬ ពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ"។

កិច្ចសម្ភាសន៍ជាមួយអ្នកទោសបានលាតត្រដាងឱ្យឃើញពីអំពើទារុណ្ណកម្ម ដែលប្រព្រឹត្តឡើងជាញឹកញាប់រួមទាំងការដាក់ខ្នោះផងដែរ។ ករណីមួយដែលគួរឱ្យកត់សំគាល់កើតឡើងក្នុងខែមករា ឆ្នាំ២០០៦ តាមសេចក្តីរាយការណ៍ថា មានអ្នកទោស ៣នាក់ ព្យាយាមរត់ចេញពីពន្ធនាគារត្រូវបានគេដាក់ខ្នោះនៅក្នុងបន្ទប់ឃុំឃាំងជិត ១ខែ ហើយអ្នកទោសទាំងនោះ ត្រូវបានគេដោះខ្នោះចេញវិញ ក្រោយពេលមានកិច្ចអន្តរាគមន៍ពីអ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ។

## របាយការណ៍ករណីអំពើទារុណកម្ម

ករណីប្រព្រឹត្តិទារុណកម្មទំនងជាមិនត្រូវបានរាយការឡើយ។ ការប្រមូលព័ត៌មានទាក់ទងនឹងអំពើទារុណកម្ម មានការលំបាកណាស់ពីព្រោះជនរងគ្រោះមួយចំនួនមិនហ៊ានរាយការទេ ដោយសារតែខ្លាចមានការវាយដំធ្វើឱ្យអាម៉ាស់ ឬ ការធ្វើបាបខាងផ្លូវចិត្តផ្សេងៗជាដើម។ ជាងនេះទៅទៀត អ្នកធ្វើទារុណ្ណកម្មបានប្រើបច្ចេកទេសពិសេសដែលមិនបន្សល់ស្លាកស្នាមដល់អ្នកសម្ភាសន៍មើលឃើញឡើយ ប៉ុន្តែ វាអាចបណ្តាលឱ្យមានរបួសផ្នែកខាងក្នុងរាងកាយយ៉ាងធ្ងន់ធ្ងរ។ កិច្ចសម្ភាសន៍ធ្វើឡើងរវាងអ្នកឃ្លាំមើល និង អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ ជួនកាលធ្វើឡើងក្នុងខណៈពេលដែលមានឆ្មាំ និង អ្នកទោសដទៃទៀតមានវត្តមាននៅក្បែរនោះដែរ។

ខាងក្រោមនេះ គឺជាឱ៊យ៉ាក្រាមដែលបង្ហាញពីរបាយការណ៍នៃអំពើទារុណកម្មដែលធ្វើឡើងដោយក្រុមអ្នកសម្ភាសន៍របស់អង្គការលីកាដូក្នុងអំឡុងពេល ៨ ឆ្នាំកន្លង។ ⋆⋆បញ្ជាក់ការចង្អុលបង្ហាញសំរាប់ឆ្នាំ២០០៦ គិតត្រឹមតែខែមករា រហូតដល់ខែតុលា ឆ្នាំ២០០៦ តែប៉ុណ្ណោះ។⋆⋆

[៥] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ ១៩៩៨

**របាយការណ៍ស្តីពីអំពើទារុណកម្មក្នុង១៨ ពន្ធនាគារ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ១៩៩៩-២០០៦**




| | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|---|---|---|---|---|
| នៅកន្លែងឃុំឃាំងនគរបាល | ៤៥០ | ៤៤២ | ២៧១ | ១១៤ | ១១៨ | ៦៥ | ១០១ | ១៦៣ |
| ពន្ធនាគារ | ៤៩ | ៤២ | ២៨ | ១០ | ២៤ | ៤១ | ៤៧ | ២២ |

## ទារុណកម្មនៅមន្ទីរឃុំឃាំងនគរបាល

អំពើទារុណកម្មអាចកើតឡើងដោយស្រួលនៅក្នុងមន្ទីរឃុំឃាំងនគរបាល ពីព្រោះជនជាប់ចោទជាធម្មតាត្រូវឃុំឃាំងដោយពុំអាចទាក់ទងទៅខាងក្រៅរួមមាន ដូចជា គ្រួសារបងប្អូន បុគ្គលិកសិទ្ធិមនុស្ស មេធាវី ឬគ្រូពេទ្យ។ ប៉ុស្តិ៍នគរបាលត្រូវបិទជិតមិនឱ្យមានអ្នកក្រៅចូលបានទេ ដូច្នេះ គេអាចមានឱកាសល្មមគ្រាប់គ្រាន់នឹងអាចធ្វើទារុណកម្មលើអ្នកទោសបានដោយគ្មានការត្រួតពិនិត្យ។ នគរបាលខ្មែរជាញឹកញាប់បានធ្វើទារុណកម្មលើជនសង្ស័យ ដើម្បីទទួលបានចំលើយសារភាព។ ទោះបីជាយ៉ាងណាក៏ដោយ ចំលើយដែលទទួលបានមិនអាចយកជាការបានឡើយ ចំលើយសារភាពមិនគួរអនុញ្ញាតិឱ្យយកទៅប្រើនៅក្នុងសវនាការតុលាការឡើយ ហើយជាលទ្ធផលនគរបាលដាក់ពន្ធនាគារជនសង្ស័យខុសទាំងប្រថុយប្រថាន។ ការចោទប្រកាន់លើអំពើទារុណកម្មនៅមន្ទីរឃុំឃាំងនគរបាលត្រូវបានប្រព្រឹត្តឡើងច្រើនជាងនៅក្នុងពន្ធនាគារ។ តារាងខាងក្រោមនេះជារបាយការណ៍បញ្ជាក់ពីទីកន្លែងដែលអំពើ ទារុណកម្មដែលច្រើនប្រព្រឹត្តឡើងនៅមន្ទីរឃុំឃាំងនគរបាល។

**របាយការណ៍អំពើទារុណកម្មនៅកន្លែងឃុំឃាំងនគរបាល ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ ២០០៤-២០០៦**

| ពន្ធនាគារ | ២០០៤ | ២០០៥ | មករា-តុលា ២០០៦ |
|---|---|---|---|
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ០ | ១៨ | ៥៦ |
| មណ្ឌលអប់រំកែប្រែទី ១ (ម-១) | ៨ | ១៤ | ៣៤ |
| មណ្ឌលអប់រំកែប្រែទី ២ (ម-២) | ៩ | ១៤ | ២៩ |

| | | | |
|---|---|---|---|
| មណ្ឌលអប់រំកែប្រែទី ៣ (ម-៣) | ២ | ៦ | ០ |
| ទួលស្លែង | ០ | ០ | ០ |
| តាខ្មៅ | ៤ | ១៤ | ២៩ |
| ក្រុងព្រះសីហនុ | ០ | ៣ | ១ |
| កំពង់ស្ពឺ | ១៤ | ១០ | ១៩ |
| កំពត | ៣ | ៣ | ០ |
| កំពង់ឆ្នាំង | ៥ | ៦ | ០ |
| កំពង់ចាម | ២ | ២ | ២ |
| កំពង់ធំ | ២ | ១ | ០ |
| កោះកុង | ១ | ៥ | ៤ |
| ពោធិ៍សាត់ | ៦ | ២ | ០ |
| បាត់ដំបង | ០ | ១ | ៨ |
| បន្ទាយមានជ័យ | ០ | ០ | ០ |
| សៀមរាប | ៩ | ២ | ១ |
| ស្វាយរៀង | ០ | ០ | ០ |
| សរុប | **៦៥** | **១០១** | **១៨៣** |

## ទារុណកម្មនៅក្នុងពន្ធនាគារ

តារាងខាងក្រោមនេះ គឺជាការសរុបបទល្មើសនៃអំពើទារុណកម្មនៅក្នុងពន្ធនាគារកត់ត្រាដោយអ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូក្នុងឆ្នាំ ២០០៤, ២០០៥ និង រយៈពេល១០ខែក្នុងឆ្នាំ ២០០៦។

**របាយការណ៍អំពើទារុណកម្មនៅក្នុងពន្ធនាគារ ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយអង្គការលីកាដូ ឆ្នាំ២០០៤-២០០៦**

| ពន្ធនាគារ | ២០០៤ | ២០០៥ | មករា-តុលា ២០០៦ |
|---|---|---|---|
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី ១ (ម-១) | ១ | ២ | ០ |
| មណ្ឌលអប់រំកែប្រែទី ២ (ម-២) | ១១ | ០ | ០ |

| | | | |
|---|---|---|---|
| ទួលស្លែង | 0 | 0 | 0 |
| មណ្ឌលអប់រំកែប្រែទី ៣ ( ម-៣) | 0 | ១៣ | 0 |
| កំពង់ចាម | 0 | 0 | 0 |
| ក្រុងព្រះសីហនុ | 0 | ៦ | 0 |
| កំពង់ស្ពឺ | 0 | 0 | 0 |
| កំពត | 0 | 0 | 0 |
| កំពង់ឆ្នាំង | 0 | 0 | 0 |
| តាខ្មៅ | 0 | 0 | ១ |
| កំពង់ធំ | ១៦ | ២៤ | ១៧ |
| កោះកុង | 0 | 0 | ៤ |
| ពោធិ៍សាត់ | ១២ | 0 | 0 |
| បាត់ដំបង | 0 | ១ | 0 |
| បន្ទាយមានជ័យ | 0 | 0 | 0 |
| សៀមរាប | ១ | ១ | 0 |
| ស្វាយរៀង | 0 | 0 | 0 |
| **សរុប** | **៤១** | **៤៧** | **២២** |

តួលេខបង្ហាញក្នុងតារាងខាងលើយើងឃើញថា អំពើទារុណកម្មក្នុងពន្ធនាគារត្រូវបានធ្វើឡើងក្នុង ៩ ពន្ធនាគារក្នុងចំណោម១៨ ពន្ធនាគារដែលអង្គការលីកាដូបានឃ្លាំមើលចាប់តាំងពីឆ្នាំ២០០៤។ តួលេខគួរឱ្យកត់សំគាល់នៃអំពើទារុណកម្ម ដែលត្រូវបានធ្វើលើអ្នកទោសនៅក្នុងពន្ធនាគារម-៣ ពន្ធនាគារខេត្តពោធិ៍សាត់ និង ពន្ធនាគារម-២-ដែលកំពុងប្រកាសអាសន្នចំពោះការឃុំឃាំងអ្នកទោស គឺមានតែមណ្ឌលកែប្រែ ម-២មួយប៉ុណ្ណោះដែលមានការដាក់ឃុំឃាំងដាច់ដោយឡែកចំពោះអ្នកទោសស្រី និង អនីតិជន។

## ការរត់គេចពីពន្ធនាគារ

តារាងខាងក្រោមនេះរាយរប់នូវហេតុការណ៍ដែលកើតឡើងទាក់ទិននឹងការរត់គេចពីពន្ធនាគារ ដែលកត់ត្រាឡើងដោយអង្គការលីកាដូពី ខែមករា ឆ្នាំ២០០៥ រហូតដល់ ខែមិថុនា ឆ្នាំ២០០៦។ នៅក្នុងប្រទេសគេដ៏ទៃការកើតឡើងនូវករណីរត់គេចពីពន្ធនាគារ គឺតែងតែមានការប្រកាសឱ្យប្រុងប្រយ័ត្នជានិច្ច ចំពោះករណីទម្លាយគុក

ដែលបង្កឱ្យមានការគំរាមទៅលើអ្នកទោសផ្សេងទៀត ឆ្មាំពន្ធនាគារ និង សាធារណៈជនផ្សេងៗ។ ជាក់ស្តែងក្នុងឆ្នាំ ២០០៥ ឆ្មាំពន្ធនាគារ ៤នាក់ ត្រូវចាប់ខ្លួនធ្វើជាចំណាប់ខ្មាំង (ថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៥ នៅពន្ធនាគារ ម-៣ ខេត្តកំពង់ចាម) និង ក្នុងឆ្នាំ ២០០៦ ឆ្មាំពន្ធនាគារ និង អ្នកទោសចំនួន ៩ នាក់ត្រូវបានសំលាប់ នៅពេលដែលប៉ូលីសធ្វើការបាញ់តបនឹងមានបម្មុះគ្រាប់បែកមួយគ្រាប់ នៅខណៈពេលដែលមានការប៉ុនប៉ងរត់ចេញពីពន្ធនាគារ (ថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០០៦ នៅពន្ធនាគារខេត្តបាត់ដំបង)។

មានរបាយការណ៏ផ្សេងទៀតទាក់ទិននឹងការធ្វើទារុណកម្ម និងសង្ស័យចំពោះការស្លាប់របស់អ្នកទោសមួយចំនួន បន្ទាប់ពីការព្យាយាមរត់គេចពីពន្ធនាគារ។ ការទម្លាយគុកបានធ្វើឱ្យមានការរឹតបន្តឹងយ៉ាងទៀតទាត់ នឹងកាត់បន្ថយពេលចេញសំរាកលំហាត់ប្រាណរបស់អ្នកទោស ការសួរសុខទុក្ខពីសាច់ញាតិ ការចូលជួបរបស់បុគ្គលិកឃ្លាំមើល និង បុគ្គលិកពេទ្យរបស់អង្គការ។ ហេតុដូច្នេះ ទើបស្ថានភាពលំបាកនៅក្នុងពន្ធនាគារកាន់តែធ្ងន់ធ្ងរឡើង។

**ការរត់គេចចេញពីពន្ធនាគារ ឆ្នាំ ២០០៥**

| ថ្ងៃ ខែ ឆ្នាំ | ពន្ធនាគារ | ចំនួនរត់គេច | ចំនួនស្លាប់ | ចាប់មកវិញ |
|---|---|---|---|---|
| ២៥ មករា ២០០៥ | កំពង់ស្ពឺ | ១ | | ០ |
| ២៣ មិនា ២០០៥ | កំពង់ចាម (ម-៣) | ៣៦ | ១៨ | ៩ |
| ១០ ឧសភា ២០០៥ | បាត់ដំបង | ១ | ០ | ១ |
| ០៤ កក្កដា ២០០៥ | កំពង់ចាម | ១៣ | ០ | ១ |
| ១៦ សីហា ២០០៥ | ពោធិ៍សាត់ | ១ | ០ | ០ |
| ០២ តុលា ២០០៥ | កំពង់ចាម | ៧ | ០ | ៧ |
| ១២ តុលា ២០០៥ | កំពង់ចាម | ១៣ | ០ | ៤ |

**ការរត់គេចចេញពីពន្ធនាគារ ឆ្នាំ ២០០៦**

| ថ្ងៃ ខែ ឆ្នាំ | ពន្ធនាគារ | ចំនួនរត់គេច | ចំនួនស្លាប់ | ចាប់មកវិញ |
|---|---|---|---|---|
| ០២ មករា ២០០៦ | ពោធិ៍សាត់ | ៤ | ០ | ០ |
| ០៨ មករា ២០០៦ | កំពង់ធំ | ៣ | ០ | ៣ |
| ០៣ កុម្ភៈ ២០០៦ | កំពង់ចាម | ១ | ០ | ១ |
| ០៦ កុម្ភៈ ២០០៦ | កោះកុង | ១ | ០ | ០ |

| | | | | |
|---|---|---|---|---|
| ០៨ កុម្ភៈ ២០០៦ | បាត់ដំបង | ១ | ០ | ០ |
| ០៨ មេសា ២០០៦ | កំពង់ធំ | ៦ | ១ | ៥ |
| ០៨ មេសា ២០០៦ | កំពត | ២ | ០ | ២ |
| ១៤ មេសា ២០០៦ | បន្ទាយមានជ័យ | ១ | ១ | ០ |
| ០៣ ឧសភា ២០០៦ | បាត់ដំបង | ១ | ០ | ០ |
| ១១ មិថុនា ២០០៦ | មណ្ឌលអប់រំកែប្រែទី ១ | ១២ | ០ | ១ |
| ១៨ មិថុនា ២០០៦ | បាត់ដំបង | ១៨ | ៩ | ៩ |
| ២៣ មិថុនា ២០០៦ | មណ្ឌលគិរី | ៣ | ១ | ៣ |

## តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ?



ឆ្មាំជាស្ត្រីនៅមណ្ឌលអប់រំកែប្រែ ទី ២

អ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូធ្វើការស៊ើបអង្កេតរាល់ការចោទប្រកាន់អំពើទារុណកម្ម ដែលបានរាយការមកពួកគេពីទីកន្លែងដែលងាយនឹងកើតឡើង ហើយព្យាយាមធ្វើអន្តរាគម៍តំណាងឱ្យអ្នកទោស។ ក្រុមពេទ្យនៃអង្គការលីកាដូ ក៏បានផ្តល់នូវជំនួយមួយចំនួនទៅឱ្យពន្ធនាគារណាដែលចាំបាច់ផងដែរ។ ក្រុមគ្រូពេទ្យនៃអង្គការលីកាដូបានផ្តល់សេវាព្យាបាល នឹងគាំទ្របញ្ហាសិទ្ធិមនុស្សមិនត្រឹមអ្នកទោសនោះទេសូម្បីឆ្មាំពន្ធនាគារក៏ទទួលបានសេវានេះដែរ។ ការងារនេះមានសារៈសំខាន់ដើម្បីធានានូវស្ថានភាពល្អក្នុងពន្ធនាគារ ក្នុងប្រទេសតាមរយៈហេតុផលផ្សេងៗទៀត។ ទី១-សេវាសំខាន់មួយ ចំនួនត្រូវបានផ្តល់ដោយអង្គការលីកាដូទៅឱ្យមន្ត្រីពន្ធនាគារក្រីក្រ និង ដើម្បីធានាបាននូវកិច្ចសហប្រត្តិបត្តការល្អ ក្នុងការចេញចូលពន្ធនាគារ។ ទី២-ដើម្បីប្រយុទ្ធប្រឆាំងនឹងការ ឆ្លងជំងឺបង្កើនអនាម័យ នឹងដោះស្រាយបញ្ហាសុខភាពផ្សេងទៀត។ អង្គការលីកាដូត្រូវព្យាបាលមនុស្សគ្រប់រូប ដែលធ្វើការនៅក្នុងពន្ធនាគារ។ ទី៣-ឆ្មាំពន្ធនាគារ និង អ្នកទោសមានទំនាក់ទំនងគ្នាហួសពីការស្មានទុក ទោះបីជាពួកគេមានអំណាចខុសគ្នាយ៉ាងណាក៏ដោយ រឿងដែលគួរឱ្យកត់សំគាល់នោះ គឺពួកគេរស់នៅលាយឡំជាមួយគ្នា។

អង្គការលីកាដូធ្វើការជាមួយទាំងអ្នកទោស និង ឆ្មាំពន្ធនាគារ ដើម្បីលើកកំពស់ការយល់ដឹងថា តើគួរតែធ្វើយ៉ាងដូចម្តេចចំពោះភាគីម្ខាងៗ។ ម៉្យាងវិញទៀត លីកាដូក៏ធ្វើការតាមរយៈការប្រឈមទៅនឹងវិប្បធមិហិង្សាដែលកើតមានឡើងនៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។

# ៧. សុខភាពខ្ញុំ

**ករណីសិក្សាទី ៦: សុខភាពនៅពន្ធនាគារ**

*ខ្ញុំមានការព្រួយបារម្ភជានិច្ចពីសុខភាព ពីព្រោះខ្ញុំកំពុងរស់នៅក្នុងស្ថានភាពមួយដ៏លំបាកនឹងមិនមានការថែទាំសុខភាពល្អប្រសើរឡើយ ។*

*នៅក្នុងពន្ធនាគារងាយនឹងមានជំងឺណាស់ ព្រោះបន្ទប់ដែលយើងស្នាក់នៅក្រខ្វក់ ហើយស្អុយឆ្អេះឆ្អាប ។ ពួកយើង មានស្ថានភាពទន់ខ្សោយដោយសារតែអាហារដែលបរិភោគតិចតួច ផឹកទឹកដែលគ្មានអនាម័យនឹងមិនបានធ្វើលំហាត់ប្រាណឱ្យបានគ្រប់គ្រាន់ ។ និយាយឱ្យចំទៅ គឺពួកយើងគ្មានទាំងសាប៊ូដុសខ្លួនផង ។ប្រសិនបើនៅក្នុងបន្ទប់មាននរណាម្នាក់ឈឺនោះអ្នកដ៏ទៃក៏នឹងឈឺដែរ ។ ជំងឺដែលខ្ញុំឃើញញឹកញាប់មានដូចជាជំងឺសើស្បែក ជំងឺផ្លូវដង្ហើម រលាកថ្លើមប្រភេទ B ជំងឺគ្រុនចាញ់ គ្រុនពោះវៀន និង ជំងឺរបេង ។ ខ្ញុំគិតថាមាន អ្នកទោសខ្លះមានផ្ទុកមេរោគអេដស៍ ហើយពួកគេមើលទៅរូបកាយខ្សោយនឹងទ្រុឌទ្រោម ។ ខ្ញុំខ្លាចណាស់ ខ្ញុំអាចនឹងមានជំងឺធ្ងន់ធ្ងរ ឬ អាចឆ្លងជំងឺផ្សេងៗ ព្រោះនៅទីនេះអ្នកមិនអាចធ្វើអ្វីបានទេប្រសិនបើអ្នកឈឺនោះ ។*

*ប្រសិនបើអ្នកឈឺនៅក្នុងពន្ធនាគារ វាពិតជាពិបាកណាស់ក្នុងការស្វែងរកការព្យាបាល ។ នៅក្នុងពន្ធនាគារមានបុគ្គលិកផ្នែកសុខភាពតែ ២ ឬ ៣នាក់ប៉ុណ្ណោះ តែពួកមេិនមែនជាគ្រូពេទ្យឡើយ ខ្ញុំគិតថាពួកគេមិនបានទទួលការហ្វឹកហ្វឺនសិក្សាបានល្អនោះទេ ។ នៅក្នុងពន្ធនាគារមានបន្ទប់ពេទ្យពិសេសមួយដែលក្នុងនោះដាក់នូវសំភារៈ និង ឧបករណ៍ពេទ្យជាច្រើន ខ្ញុំឮមកថានៅពន្ធនាគារ ផ្សេងទៀតមិនមានបន្ទប់ពេទ្យ ឬ សូម្បីតែថ្នាំពេទ្យសោះឡើយ ។*

*ប្រសិនបើ អ្នកឈឺខ្លាំងហើយមានលទ្ធភាពចំណាយលុយសំរាប់ព្យាបាល ឆ្មាំពន្ធនាគារនឹងបញ្ជូនអ្នកតាមម៉ូតូ ឬ ឡានទៅមន្ទីរពេទ្យនៅក្រៅពន្ធនាគារ ។ ប្រសិនបើមានរឿងនេះកើតឡើង ឆ្មាំពន្ធនាគារនឹងតាមឃ្លាំមើល ហើយអ្នកនឹងត្រូវគេដាក់ខ្នោះជាប់ទៅនិងគ្រែពេទ្យដែរ-ទោះជាយ៉ាងណាក្តី ខ្ញុំឮថាមានអ្នកទោសខ្លះបានរត់គេចចេញពីមន្ទីរពេទ្យដែរ ។ ប្រសិនបើអ្នកមានលុយអ្នកអាចពឹងពាក់ពេទ្យពន្ធនាគារព្យាលបាលឱ្យក៏បាន ។ ប៉ុន្តែ សេវានេះមិនមានគ្រប់ពេលទេពីព្រោះបុគ្គលិកផ្នែកសុខភាពរបស់ពន្ធនាគារមិនមានតួនាទីនៅក្នុងពន្ធនាគារគ្រប់ពេលវេលាឡើយ ។ មានអ្នកខ្លះបានប្រាប់ខ្ញុំពីករណី ដែលមានអ្នកទោសខ្លះបានស្លាប់ដោយសារតែពួកគេមានជំងឺធ្ងន់ធ្ងរពេក ហើយត្រូវការគ្រូពេទ្យជាបន្ទាន់ ប៉ុន្តែ បើធ្លាក់*

ខ្លួនឈឺនៅពេលយប់ជ្រៅ នោះគ្មាននរណាម្នាក់ផ្តល់ការព្យាបាលជួយអ្នកបានឡើយ ។ ខ្ញុំសង្ឃឹមថា រឿងនេះនឹងមិនកើតឡើងចំពោះខ្ញុំឡើយ ។

ពេលខ្លះមានគ្រូពេទ្យអង្គការបានមកពន្ធនាគារ ផ្តល់ការពិនិត្យសុខភាពដោយមិនគិតថ្លៃ ។ ជាទូទៅមានពេទ្យ ២នាក់ និង សហការី ១នាក់មកពីអង្គការ ។ ពួកគេផ្តល់ការពិនិត្យសុខភាពទូទៅជូនអ្នកទោស និង ឆ្មាំពន្ធនាគារ ហើយក្រុមពេទ្យបានចែកថ្នាំ និងអាហារឱ្យដល់អ្នកទោសផងដែរ ។ ប្រសិនបើមាននរណាម្នាក់ឈឺខ្លាំងពេទ្យអង្គការអាចស្នើសុំអនុញ្ញាតិប្រធានពន្ធនាគារ ដើម្បីបញ្ជូនអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យ ដើម្បីព្យាបាល-ប៉ុន្តែករណី នេះកម្រកើតមានណាស់ ។

អ្នកត្រូវតែប្រុងប្រយ័ត្នចំពោះការនិយាយស្តីនៅពេលពិនិត្យសុខភាព ព្រោះឆ្មាំពន្ធនាគារតែងតែនៅឃ្លាំមើលអ្នកជានិច្ច ។ ប្រសិនបើ ឆ្មាំពន្ធនាគារបានឮអ្វីដែលយើងនិយាយជាមួយបុគ្គលិកអង្គការប្រាប់អំពីស្ថានភាពលំបាក ឬ អំពើទារុណកម្ម ពួកគេនឹងវាយយើងបន្ទាប់ពីនោះ ។ អង្គការចុះទៅពន្ធនាគាររៀងរាល់ខែ ប៉ុន្តែ អាចត្រឹមតែជួបអ្នកទោសមួយចំនួនតែប៉ុណ្ណោះ-គឺប្រហែលពី ១៥០ ទៅ ២០០នាក់ ហេតុដូច្នេះ អ្នកប្រហែលអាចមិនមែនជាអ្នកមានសំណាងទទួលបានការពិនិត្យសុខភាព ។

## បញ្ហាសុខភាព

បញ្ហាសុខភាពនៅក្នុងពន្ធនាគារកើតឡើងជាធម្មតាក្នុងចំណោមអ្នកទោសខ្មែរ បរិយាកាសនៅក្នុងពន្ធនាគារបានធ្វើឱ្យអ្នកទោសទាំងនោះជួបប្រទះនូវបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ។ ខាងក្រោមនេះ គឺជាការបង្ហាញពីទិដ្ឋភាពរស់នៅក្នុងពន្ធនាគារ ដែលប្រឈមនឹងបញ្ហាសុខភាពដ៏យ៉ាប់យ៉ឺន:

- **ភាពចង្អៀតណែន:** បង្កឱ្យមានការឆ្លងជំងឺកាន់តែខ្លាំងឡើងៗ។
- **កង្វះអនាម័យ:** បង្កឱ្យមានការឆ្លងមេរោគ និង ប៉ារ៉ាស៊ីត។
- **ទឹកបរិភោគគ្មានអនាម័យ:** បង្កឱ្យមានជំងឺរាគរូស គ្រុនពោះវៀន រាគមួល និង មានមេរោគប៉ារ៉ាស៊ីតនៅក្នុងខ្លួន។
- **ខ្វះខាតម្ហូបអាហារ:** មិនមានវីតាមីនគ្រប់គ្រាន់ ធ្វើឱ្យសុខភាពចុះខ្សោយងាយឆ្លងជំងឺផ្សេងៗ។
- **បន្ទប់ឃុំឃាំងមិនមានខ្យល់អាកាសគ្រប់គ្រាន់:** ធ្វើឱ្យមានការសាយភាយជំងឺឆ្លងផ្សេងៗ និង បញ្ហាផ្លូវដង្ហើមដូចជាជំងឺរលាកច្រមុះ និង រលាកទងសួត។
- **ពេលវេលាសំរាកលំហាត់ប្រាណមិនគ្រប់គ្រាន់:** ខ្វះខាតការធ្វើលំហាត់ប្រាណ និង ការស្រូបយកពន្លឺព្រះអាទិត្យដែលបង្កឱ្យមានជំងឺសើស្បែក និងមានការលំបាកជាខ្លាំងដល់អ្នកទោសក្នុងការថែរក្សាសុខភាពផ្ទាល់ខ្លួន។
- **ខ្វះខាតសេវាព្យាបាល:** បង្កឱ្យមានការសាយភាយជំងឺឆ្លងផ្សេងៗ និង បញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ-អ្នកទោសមួយចំនួនមិនទទួលបាននូវសេវាថែទាំសុខភាព។
- **អំពើទារុណកម្ម និងអំពើហិង្សា:** ផ្នែករាងកាយទទួលការប៉ះទង្គិច ផ្នែកស្មារតីក៏ទទួលរងនូវ ការតក់ស្លុតដែលអាចជះឥទ្ធិពលដល់លទ្ធភាពក្នុងការថែទាំសុខភាពផ្ទាល់ខ្លួនរបស់អ្នកទោស។

## ការស្លាប់នៅក្នុងពន្ធនាគារ

តារាងខាងក្រោមបង្ហាញពីចំនួនរបស់អ្នកទោសស្លាប់នៅក្នុងមន្ទីរឃុំឃាំង (ពន្ធនាគារ និង មន្ទីរពេទ្យ) មានចំនួនកើនឡើងលឿនជាងចំនួននៃកំណើនចំនួនអ្នកទោសនៅក្នុងពន្ធនាគារ។

**ការស្លាប់នៅក្នុងមន្ទីរឃុំឃាំងក្នុងចំណោមពន្ធនាគារ១៨ ដែលឃ្លាំមើល ដោយអង្គការលីកាដូ ឆ្នាំ២០០២-ឆ្នាំ២០០៦**

| ពន្ធនាគារ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ មករា-តុលា |
|---|---|---|---|---|---|
| នគរបាយុត្តិធមិ ( ប៉េហ្ស៊ី) | ០ | ០ | ១ | ១ | ០ |
| មណ្ឌលអប់រំកែប្រែទី ១ ( ម-១) | ១៧ | ១៣ | ២២ | ១៨ | ?* |
| មណ្ឌលអប់រំកែប្រែទី ២ ( ម-២) | ១ | ៥ | ៣ | ៥ | ៤ |
| មណ្ឌលអប់រំកែប្រែទី ៣ ( ម-៣) | ០ | ២ | ២ | ៣៦ | ២៣ |
| ទួលស្លែង | ០ | ០ | ០ | ០ | ០ |
| តាខ្មៅ | ១ | ២ | ៣ | ៤ | ២ |
| ក្រុងព្រះសីហនុ | ៣ | ១ | ១ | ១ | ១ |
| កំពង់ស្ពឺ | ៣ | ២ | ២ | ៤ | ១ |
| កំពត | ៣ | ២ | ១ | ៤ | ៣ |
| កំពង់ឆ្នាំង | ១ | ១ | ២ | ១ | ១ |
| កំពង់ចាម | ០ | ៣ | ៣ | ៩ | ១០ |
| កំពង់ធំ | ០ | ៣ | ២ | ០ | ១ |
| កោះកុង | ០ | ២ | ២ | ០ | ៤ |
| ពោធិ៍សាត់ | ០ | ១ | ២ | ១ | ១ |
| បាត់ដំបង | ៦ | ៤ | ៦ | ៩ | ៩ |
| បន្ទាយមានជ័យ | ៣ | ២ | ៣ | ៥ | ២ |
| ស្រៀមរាប | ៤ | ២ | ១ | ២ | ៤ |
| ស្វាយរៀង | ១ | ១ | ២ | ០ | ០ |
| សរុប | **៤៣** | **៤៦** | **៥៨** | **១០០** | **៤០** |

*ម-១ មិនបានផ្តល់ព័ត៌មានណាមួយទាក់ទងនឹងការស្លាប់ក្នុងពន្ធនាគារមកអ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូឡើយ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០០៥ ។

ពន្ធនាគារធំៗបានចុះចំនួនអ្នកស្លាប់ច្រើនជាងគេក្នុងរវាង ៤ ឆ្នាំកន្លងទៅ រួមបញ្ចូលទាំងពន្ធនាគារ ម-១ មានចំនួន ៧០ នាក់ និង ម-៣ ចំនួន ៦៣នាក់បានស្លាប់។ ទាក់ទងទៅនឹងកំណើនអ្នកទោសក្នុងពន្ធនាគារ មានពន្ធនាគារនៅតាមបណ្ដាខេត្តមួយចំនួនមានការកើនឡើងចំពោះចំនួនអ្នកស្លាប់ខ្ពស់ដូចគ្នា មានដូចជានៅពន្ធនាគារខេត្តកោះកុង ខេត្តកំពង់ធំ ក្រុងព្រះស៊ីហានុ និង ខេត្តកំពត។

## តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ?

លីកាដូមានជំនឿយ៉ាងមុតមាំថា ជនគ្រប់រូបទាំងអស់រួមទាំងអ្នកជាប់ឃុំឃាំងនឹងទទួលបានសិទ្ធិថែទាំសុខភាពជាមូលដ្ឋាន។ ក្រោយពេលបង្កើតការិយាល័យពេទ្យនៅក្នុងឆ្នាំ ១៩៩៣ អង្គការលីកាដូបានចាប់ផ្ដើមធ្វើការលើពន្ធនាគារចំនួនពីរនៅទីក្រុងភ្នំពេញ។ ដោយស្របពេលគ្នានោះ ពន្ធនាគារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានជួបប្រទះនូវបញ្ហាសុខភាពមួយចំនួនដែរ។ រយៈជាងមួយទសវត្សកន្លងទៅ ការិយាល័យពេទ្យនៃអង្គការលីកាដូ គឺមានការងារមមាញឹកជាងគេនៅក្នុងអង្គការ ដែលត្រូវចុះទៅពន្ធនាគារទាំង ១២ នៅក្នុងប្រទេសទាំងមូលជារៀងរាល់ខែ[១០] ដែលមានចំនួនអ្នកទោសសរុប ១.៧០០នាក់។ នៅពេលចុះទៅពិនិត្យម្ដងៗត្រូវចំណាយពេល ១ថ្ងៃ ប៉ុន្តែសំរាប់ពន្ធនាគារណា ដែលមានទំហំធំត្រូវចំណាយពេលចាប់ពី ២ ឬ ៣ថ្ងៃ។




[១០] ពន្ធនាគារតាខ្មៅ, តាកែវ, ព្រៃវែង, ស្វាយរៀង, កំពង់ធំ, កំពង់ចាម, កោះកុង, កំពង់ស្ពឺ, ក្រុងព្រះសីហនុ, ពោធិ៍សាត់, បាត់ដំបង និងពន្ធនាគារពីរទៀតនៅក្រុងភ្នំពេញ-នគរបាលយុត្តិធម៌ និង ទួលស្លែង ។

ជារៀងរាល់សប្តាហ៍ ការិយាល័យពេទ្យនឹងរៀបចំការចុះសួរសុខទុក្ខ ៣ ឬ ៤ ពន្ធនាគារ។ ហើយក្នុងការចុះទៅជួប ត្រូវបានរៀបចំទុករួចជាស្រេចរវាងពន្ធនាគារអ្នកស្រាវជ្រាវ មន្ត្រីពន្ធនាគារ និង ក្រុមពេទ្យ។

ក្រុមគ្រូពេទ្យដែលចុះសួរសុខទុក្ខមានចំនួន ២នាក់ និង សហការី ១នាក់ ដោយយកទៅជាមួយដោយថ្នាំពេទ្យ សំភារៈពេទ្យ ដូចជាបង់រុំរបួស និង អាហារជាដើម។ គោលបំណងនៃការចុះសួរសុខទុក្ខ គឺដើម្បីផ្តល់ការពិនិត្យសុខភាពទូទៅដល់អ្នកទោស។ ការត្រួតពិនិត្យសុខភាពមានផ្តល់ដូចជា វេជ្ជបញ្ជានៃការព្យាបាល (ដែលអនុញ្ញាតិឱ្យប្រើប្រាស់ដោយមន្ត្រីសុខភាពនៅពន្ធនាគារ) ក្នុងករណីអ្នកទោសមានជំងឺធ្ងន់ធ្ងរត្រូវបញ្ជូនទៅព្យាបាលជាបន្ទាន់ ឬ បញ្ជូនទៅកាន់មន្ទីរពេទ្យ (ការបញ្ជូនទៅត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នក្រោមការត្រួតពិនិត្យរបស់ប្រធានពន្ធនាគារ ចំណែកក្រុមពេទ្យគ្រាន់តែធ្វើជាសំណើរតែប៉ុណ្ណោះ)។ ក្រុមពេទ្យក៏ឆ្លៀតឱកាសធ្វើការតាមដាន នឹងចែកថ្នាំឱ្យអ្នកទោស ហើយការធ្វើនេះមិនទាមទារឱ្យមានការស៊ីសំណូកឡើយ។



ពេទ្យលីកាដូធ្វើការពិនិត្យសុខភាព, មិថុនា ឆ្នាំ ២០០៦

ការត្រួតពិនិត្យសុខភាពជាធម្មតាធ្វើឡើងនៅក្នុងបន្ទប់ឃុំឃាំង។ ទោះជាយ៉ាងណាក្តី ពេលខ្លះការពិនិត្យសុខភាពអាចធ្វើនៅខាងក្រៅបន្ទប់ឃុំឃាំងដែរ។ នៅរៀងរាល់ពេលចុះទៅពិនិត្យ ក្រុមគ្រូពេទ្យអាចជួបអ្នកទោសប្រហែល ២០០នាក់។

បន្ថែមពីលើកាលវិភាគប្រចាំខែ ក្រុមពេទ្យអាចព្យាបាលករណីពិសេសដែលចាំបាច់ និងបន្ទាន់ដែលអនុញ្ញាតឱ្យក្រុមពេទ្យធ្វើការតាមដានសុខភាពដល់អ្នកទោសណា ដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរ ឬ ក៏ស្ថានភាពបន្ទាន់ណាមួយ។ ក្នុងកំឡុងខែមករា និង ខែមិថុនា ឆ្នាំ២០០៦ ការិយាល័យពេទ្យនៃអង្គការលីកាដូ សំរេចបានភារៈកិច្ចដូចខាងក្រោម នេះ :

- អ្នកទោសចំនួន ៣.៥៧៣ នាក់ (រួមទាំងអ្នកទោសស្ត្រីចំនួន ៣៨៨ នាក់) និង មន្ត្រីពន្ធនាគារ ៤០៦ នាក់ (រួមទាំងមន្ត្រីពន្ធនាគារស្ត្រីចំនួន ៤៥ នាក់) ក៏ទទួលបានការពិនិត្យសុខភាព។
- ផ្តល់គ្រាប់ពូជ និង ឧបករណ៍បំរើការដាំដុះទៅឱ្យអ្នកទោសក្នុងពន្ធនាគារចំនួន ១៥ ដើម្បីបង្កបង្កើតផលនឹងផ្លែទាំសួនដំណាំ។

អនុវត្តកម្មវិធីអនាម័យក្នុងពន្ធនាគារមួយដើម្បីព្យាបាលជំងឺកមរមាស់។ កម្មវិធីនេះរួមបញ្ចូលទាំងកម្មវិធីហ្វឹកហ្វឺនពីវិធីបោកគក់សំលៀកបំពាក់ សំអាតបន្ទប់ឃុំឃាំង អគារចង្ក្រានបាយថ្មីមួយ សំអាតបង្គន់ ប្រព័ន្ធលូទឹកស្អុយ នឹងអប់រំអ្នកទោសទាំងអស់ និង មន្ត្រីពន្ធនាគារឱ្យយល់ដឹងទូទៅពីសុខភាពអនាម័យផ្ទាល់ខ្លួន។

# ៨.ការយល់ឃើញផ្សេងគ្នាចំពោះ ស្ត្រី កុមារ និង អនីតិជន

## ករណីសិក្សាទី ៧: ស្ត្រីក្នុងពន្ធនាគារ

*នាងខ្ញុំឈ្មោះ សំ អាង អាយុ៣៥ ឆ្នាំ។ នាងខ្ញុំរស់នៅក្នុងពន្ធនាគារមួយជាមួយអ្នកទោសបុរស និង ស្ត្រីផងដែរ។*

*មើលពីបន្ទប់ឃុំឃាំង ខ្ញុំអាចឃើញអ្នកទោសបុរសឃុំឃាំងក្នុងបន្ទប់ពួកគេ។ បន្ទប់ឃុំឃាំងស្ត្រីស្ថិតនៅជិតបំផុតទៅនឹងបន្ទប់ឃុំឃាំងបុរស។ យើងនៅអគារផ្សេងគ្នា ប៉ុន្តែ ស្ថិតនៅជាប់គ្នា។ ខ្ញុំមិនសូវជាភ័យខ្លាចពេកទេចំពោះអ្នកទោសបុរសដែលឃុំនៅក្បែរនោះ ព្រោះពួកគេត្រូវបានចាក់សោរឱ្យនៅក្នុងបន្ទប់ឃុំឃាំងស្ទើរតែគ្រប់ពេល។ ទោះបីជាយ៉ាងណា ខ្ញុំដឹងថាពួកគេភាគច្រើនជាឃាតករ និង ឧក្រិដ្ឋជនរំលោភសេពសន្ថវៈ ហើយប្រសិនបើពួកគេមានឱកាស ខ្ញុំជឿថា ពួកគេនឹងប្រព្រឹត្តអំពើមិនគប្បីណាមួយ។ បញ្ហានេះពិតជាធ្វើឱ្យយើងព្រួយបារម្ភណ៍នៅពេលខ្លះ។*

*ខ្ញុំមិនប្រាកដទេចំពោះឆ្មាំពន្ធនាគារជាបុរស។ ខ្ញុំគ្រាន់តែជឿថា ពួកគេអាចធ្វើបាបយើង ប្រសិនបើពួកគេចង់ធ្វើ។ ជាធម្មតា ខ្ញុំព្យាយាមនៅឆ្ងាយពីឆ្មាំពន្ធនាគារទាំងបុរសទាំងស្ត្រី ថ្វីត្បិតបើពេលខ្លះ ខ្ញុំដឹងថាមានអ្នកទោសស្ត្រីបោកគក់សម្លៀកបំពាក់ឱ្យឆ្មាំពន្ធនាគារ ដើម្បីរកកម្រៃបន្ថែមក៏ដោយ។*

*អ្នកទោសស្ត្រីអាចចេញដើរមកខាងក្រៅបន្ទប់ឃុំឃាំងបានស្ទើរតែគ្រប់ពេល។ ខ្ញុំគិតថា យើងងាយស្រួលឃ្លាំមើលជាងបុរស។ អ្នកទោសបុរសត្រូវដាក់វេនគ្នាចេញពេលសំរាកហាត់ប្រាណ។ ដូច្នេះស្ទើរតែគ្រប់ពេលមានអ្នកទោសបុរសខ្លះនៅក្នុងបរិវេណសំរាកហាត់ប្រាណ ស្របពេលដែលអ្នកទោសស្ត្រីនៅទីនោះដែរ។ អ្នកទោសបុរស និង ស្ត្រីត្រូវបានអនុញ្ញាតឱ្យជជែកគ្នាពេលសំរាកហាត់ប្រាណ។*

*អ្នកទោសបុរសជាធម្មតាងូតទឹកខាងក្រៅបន្ទប់ឃុំឃាំង ប៉ុន្តែ សំរាប់អ្នកទោសជាស្ត្រីវិញ ត្រូវងូតទឹកខាងក្នុងបន្ទប់ឃុំឃាំងជាមួយទឹកក្នុងធុង។ វាពិបាកសំរាប់យើងផងដែរ ក្នុងការថែរក្សារាងកាយរបស់យើងឱ្យបានស្អាត ពីព្រោះយើងពុំមានសំឡីអនាម័យ។ សំរាប់អ្នកទោសជាស្ត្រីខ្លះ ដែលមានក្រុមគ្រួសារមកសួរសុខទុក្ខញឹកញាប់ប្រហែលជាទទួលបានសំឡីអនាម័យខ្លះ ឬ ប្រសិនបើអ្នកមានលុយអ្នកអាចទិញវាពីឆ្មាំពន្ធនាគារស្ត្រី បើពុំដូច្នេះទេ អ្នកត្រូវប្រើក្រណាត់ជំនួស។*

## អ្នកទោសរស់នៅជាមួយកូនក្មេង

មានអ្នកទោសស្ត្រីចំនួន ៩នាក់នៅក្នុងបន្ទប់ឃុំឃាំងជាមួយខ្ញុំ ដូច្នេះ វាមិនសូវជាចង្អៀតខ្លាំងពេកទេ ។ ខ្ញុំដឹងថា មានអ្នកទោសបុរសមានដល់ទៅ ៣០ ទៅ ៤០ នាក់ក្នុងបន្ទប់ឃុំឃាំងមួយ ។ ស្ត្រីបីនាក់នៅបន្ទប់ឃុំឃាំងជាមួយខ្ញុំមានកូនតូចៗនៅជាមួយពួកគេ ។ ស្ត្រីម្នាក់មានកូនប្រុសម្នាក់អាយុបីឆ្នាំ ចំណែកឯស្ត្រីពីរនាក់ទៀតមានកូនស្រីមួយម្នាក់ ដែលមានអាយុមួយឆ្នាំ ។ វត្តមានរបស់ក្មេងៗធ្វើឱ្យបន្ទប់ឃុំឃាំងមានលក្ខណៈចង្អៀតជាងមុនបន្តិច ប៉ុន្តែ គួរឱ្យរីករាយចំពោះវត្តមានពួកគេ ។ នេះបញ្ជាក់ថា បន្ទប់ដែលយើងរស់នៅមិនមានលក្ខណៈដូចជាបន្ទប់ក្នុងពន្ធនាគារពេកនោះទេ ។

ទោះជាយ៉ាងណាក្តី វាជារឿងគួរឱ្យរីករាយការដែលអ្នកមានកូននៅជាមួយក្នុងពន្ធនាគារ ប៉ុន្តែ ខ្ញុំគិតថា វាប្រហែលជាមានការលំបាកក្នុងការចិញ្ចឹមពួកគេ ។ ប្រសិនបើអ្នកសំណាងល្អ មានក្រុមគ្រួសាររស់នៅខាងក្រៅពន្ធនាគារ ហើយពួកគេអាចជួយចិញ្ចឹមកូនរបស់អ្នកបានវារីតតែប្រសើរជាង ។ ដោយអ្នកពុំចាំបាច់មើលថែទាំ ឬ ព្រួយបារម្ភរណ៍ពីកូនរបស់អ្នក ហើយកូនអ្នកនឹងបានទៅសាលារៀន ។ អ្នកទោសស្ត្រីដែលមានកូនតូចនៅជាមួយ គឺដោយពួកគេគ្មានក្រុមគ្រួសារ ឬ អ្នកពឹងអាស្រ័យឱ្យជួយមើលថែរក្សាកូនរបស់គេបាន ។ ខ្ញុំមានអារម្មណ៍អាណិតចំពោះក្មេងៗទាំងនោះ ព្រោះថានៅក្នុងពន្ធនាគារ អ្នកនៅតែទទួលបានរបបអាហារក្នុងបរិមាណដដែល បើទោះបីជាអ្នកទោសស្ត្រីមានកូននៅជាមួយក៏ដោយ ។ នៅពន្ធនាគារពុំមានសាលារៀនសំរាប់ក្មេងៗ ឬ អ្វីផ្សេងៗសំរាប់ឱ្យពួកគេធ្វើ ឬ លេងកំសាន្តឡើយ ។ ពេលខ្លះអ្នកទោសស្ត្រីដែលរស់នៅជាមួយបានចែករំលែករបបអាហារឱ្យទៅក្មេងៗដែរ ។

ជូនកាលអង្គការក្រៅរដ្ឋាភិបាលផ្តល់អាហារ និង សម្ភារៈបន្ថែមដល់អ្នកទោសដែលមានកូនរស់នៅជាមួយ ។ ពួកគេទាំងនោះទទួលបានម្សៅទឹកដោះគោ អង្ករ ត្រីងៀត និង សំលៀកបំពាក់សំរាប់កូនរបស់គេ ។ អាហារ និង សំភារះទាំងនោះជានិច្ចជាកាលមិនគ្រប់គ្រាន់សំរាប់ពួកគេឡើយ ហើយពេលខ្លះឆ្មាំពន្ធនាគារបានដកហូតខ្លះទៀតផង ប៉ុន្តែ អំណោយទាំងនោះពិតជាបានជួយដល់ម្តាយរបស់ក្មេង ។ ក្នុងពន្ធនាគារ វាជារឿងពិបាក ក្នុងការទទួលបាននូវសំលៀកបំពាក់បន្ថែមសំរាប់កូនក្មេង ប្រសិនបើ អ្នកគ្មានលុយច្រើន ។

វាក៏ជាការលំបាកផងដែរប្រសិនបើអ្នកមានផ្ទៃពោះ ។ អ្នកមិនទទួលបាននូវអាហារបំប៉នបន្ថែម ឬក៏ការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រឡើយ ហើយអ្នកត្រូវសំរាលកូននៅក្នុងពន្ធនាគារទៀតផង ។ ប្រសិនបើអ្នកមានសំណាង អង្គការក្រៅរដ្ឋាភិបាលប្រហែលជាអាចជួយចេញថ្លៃសេវាមន្ទីរពេទ្យឱ្យអ្នក ប៉ុន្តែ រឿងបែបនេះមិនមានកើតឡើងញឹកញាប់នោះទេ ។ ពេលអ្នកសំរាលកូននៅក្នុងពន្ធនាគារជាធម្មតាគ្មានគ្រូពេទ្យជំនាញជួយអ្នកឡើយ ក្រៅពីបុគ្គលិកផ្នែកសុខភាពរបស់ពន្ធនាគារ ប៉ុន្តែ បុគ្គលិកនោះ

*ប្រហែលជាមិនអនុវត្តតាមតួនាទីរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនឡើយ ។ ប្រសិនមានបញ្ហាពេលមានផ្ទៃពោះ ខ្ញុំគិតថាវាមិនងាយស្រួលក្នុងការបញ្ជូនទៅមន្ទីរពេទ្យឡើយ ។*

*ជាមួយនេះផងដែរ ដោយសារតែយើងមិនទទួលបានអាហារគ្រប់គ្រាន់ ម្តាយខ្លះមានសុខភាពទន់ខ្សោយយ៉ាងខ្លាំង ហើយមិនអាចបំបៅដោះកូនដោយទឹកដោះបានទៀតផង ។ តែទោះជាយ៉ាងណាម្តាយខ្លះចូលចិត្តចិញ្ចឹមកូនដោយម្សៅទឹកដោះគោ ហេតុដូច្នេះ ការបំបៅកូនដោយទឹកដោះម្តាយមិនជាបញ្ហាឡើយ ។ តែទោះបីជាយ៉ាងណាក្តី ម្តាយរបស់ក្មេងត្រូវទិញអុស ឬ ធ្យូងពីឆ្មាំពន្ធនាគារ ដើម្បីដាំទឹកក្តៅ ឬ ត្រូវឱ្យលុយទៅពួកគេជាការដោះដូរនៃការផ្តល់នូវទឹកស្អាតសំរាប់ឆុងទឹកដោះគោឱ្យកូន ។ វាអាចមានតំលៃខ្ពស់ខ្លាំងណាស់ ។ ប្រសិនបើអ្នកគ្មានលទ្ធភាពទទួលបាននូវទឹកស្អាតទេ អ្នកត្រូវតែប្រើទឹកផ្សេងៗដែលអាចរកមកជំនួស ដោយមូលហេតុទាំងនេះដែលអាចបង្កឱ្យក្មេងឈឺ ។*

## ការឃុំឃាំងស្ត្រីដាច់ដោយឡែក

បទបញ្ញត្តិអប្បបរមារបស់អង្គការសហប្រជាជាតិដើម្បីប្រព្រឹត្តលើអ្នកទោស ត្រង់ចំណុច ៨ (ក) ចែងថា "តាមលទ្ធភាពដែលអាចធ្វើបាន បុរស និង ស្ត្រីត្រូវឃុំឃាំងនៅកន្លែងដាច់ដោយឡែកពីគ្នា។ ករណីដែលកន្លែងឃុំឃាំងទទួលឱ្យបុរស និង ស្ត្រីនៅក្នុងឃុំជាមួយគ្នា ទីតាំងសម្រាប់ឃុំឃាំងស្ត្រីទាំងមូលត្រូវដាក់ឱ្យដាច់ពីកន្លែងឃុំឃាំងបុរស"។ យោងតាមទីតិវិធីពន្ធនាគារកម្ពុជាលេខ៣បានចែងថា ត្រូវឃុំឃាំងស្ត្រីនៅអគារដាច់ដោយឡែកពីបុរស។ ប៉ុន្តែជាទូរទៅ ការឃុំឃាំងច្រើនតែធ្វើឡើងដោយរំលោភលើមាត្រាចែងនេះ។

- ពន្ធនាគារចំនួន ៥ (ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តស្វាយរៀង និង មន្ទីរឃុំឃាំងរបស់នគរបាលយុត្តិធមិប៉េហ្ស៊ី) មានបន្ទប់ឃុំឃាំងអ្នកទោសស្ត្រីនៅជាប់បន្ទប់ឃុំឃាំងអ្នកទោសបុរស។ ពន្ធនាគារចំនួន ១០ក្នុងចំណោមពន្ធនាគារ ១៨ ដែលឃ្លាំមើលដោយលីកាដូ អ្នកទោសស្ត្រីត្រូវបានឃុំឃាំងក្នុងអគារផ្សេងពីបុរស (មណ្ឌលអប់រំកែប្រែទី២ ពន្ធនាគារខេត្តកណ្ដាល ពន្ធនាគារក្រុងព្រះសីហនុ ពន្ធនាគារខេត្តកំពង់ស្ពឺ ពន្ធនាគារខេត្តកំពត ពន្ធនាគារខេត្តកំពង់ឆ្នាំង ពន្ធនាគារខេត្តកំពង់ធំ ពន្ធនាគារខេត្តកោះកុង ពន្ធនាគារខេត្តពោធិ៍សាត់ ពន្ធនាគារខេត្តបន្ទាយមានជ័យ)។ ចំណែកឯពន្ធនាគារ៣ផ្សេងទៀត ពុំមានអ្នកទោស ស្ត្រី (មណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី៣ និង ពន្ធនាគារទួលស្លែង)។



*បន្ទប់ឃុំឃាំងអ្នកទោសស្ត្រីជានិច្ចជាកាលនៅជាប់បន្ទប់ឃុំឃាំងអ្នកទោសបុរស*

- ទោះបីជាអ្នកទោសស្ត្រីត្រូវបានឃុំឃាំងក្នុងបន្ទប់ផ្សេងក៏ដោយ ក៏ឆ្មាំពន្ធនាគារបុរសឃ្លាំមើលពួកគេជាញឹកញាប់។
- ថ្វីត្បិតបើជាទូទៅអ្នកទោសស្ត្រីត្រូវបានឃុំឃាំងក្នុងបន្ទប់ផ្សេងពីអ្នកទោសបុរសក្តី ក៏អ្នកទោសបុរសវ័យចាស់ជរា ឬ សុខភាពទន់ខ្សោយត្រូវបានគេឃុំឃាំងជាមួយបន្ទប់ស្ត្រីដែរ ដើម្បីការពារពួកគេពីអ្នកទោសដ៏ទៃទៀត (ករណីនេះទើបកើតមានឡើងនៅពន្ធនាគារខេត្តពោធិ៍សាត់)។

លើកលែងតែនៅមណ្ឌលអប់រំកែប្រែទី២ ដែលមានពន្ធនាគារសំរាប់ឃុំឃាំងអ្នកទោសអនីតិជន និង ស្ត្រី។

មកទល់ខែតុលា ឆ្នាំ២០០៦ អ្នកទោសស្ត្រីមានត្រឹមតែ ៦.៣% នៃចំនួនអ្នកទោសសរុបក្នុងពន្ធនាគារ ១៨ ដែលឃ្លាំមើលដោយលីកាដូ ។

**ចំនួនអ្នកទោសស្ត្រីក្នុងពន្ធនាគារទាំង១៨ ឃ្លាំមើលដោយលីកាដូ ចាប់តាំងពីឆ្នាំ២០០១-២០០៦**[១១]




**ចំនួនអ្នកទោសស្ត្រីក្នុងពន្ធនាគារនីមួយៗក្នុងចំណោមពន្ធនាគារទាំង១៨**

**ឃ្លាំមើលដោយ លីកាដូ ចាប់តាំងពីឆ្នាំ ២០០៤-២០០៦**[១២]

| ពន្ធនាគារ | ២០០៤ | ២០០៥ | មករា-តុលា ២០០៦ |
|---|---|---|---|
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ៥ | ៦ | ៩ |
| មណ្ឌលអប់រំកែប្រែទី១ (ម-១) | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ១៦៦ | ២៥៣ | ២៥៦ |
| ទួលស្លែង | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី៣ (ម-៣) | ០ | ០ | ០ |
| ខេត្តកំពង់ចាម | ១៤ | ១៦ | ២៨ |
| ក្រុងព្រះសីហនុ | ២១ | ១០ | ៧ |
| ខេត្តកំពង់ស្ពឺ | ៥ | ៨ | ៧ |

[១១] តួលេខទាំងអស់គិតមកដល់ខែ ធ្នូ លើកលែងតែឆ្នាំ២០០៦ គិតត្រឹមខែ តុលា

[១២] ទិន្នន័យដូចគ្នា

| | | | |
|---|---|---|---|
| ខេត្តកំពត | ១៣ | ១៣ | ១៤ |
| ខេត្តកំពង់ឆ្នាំង | ៦ | ៩ | ៩ |
| ខេត្តកណ្តាល (តាខ្មៅ) | ២០ | ១៨ | ១៩ |
| ខេត្តកំពង់ធំ | ១១ | ១៤ | ១១ |
| ខេត្តកោះកុង | ៦ | ១១ | ១៤ |
| ខេត្តពោធិ៍សាត់ | ២៩ | ១០ | ៥ |
| ខេត្តបាត់ដំបង | ២១ | ៤៥ | ៤៦ |
| ខេត្តបន្ទាយមានជ័យ | ២៣ | ៣៥ | ៤៥ |
| ខេត្តសៀមរាប | ២ | ៥២ | ៥៦ |
| ខេត្តស្វាយរៀង | ៣ | ៦ | ១០ |
| **សរុប** | **៣៨៥** | **៥០៦** | **៥៣៦** |

## ការរំលោភបៀតបៀនផ្លូវភេទ និង រូបរាងកាយ

ជាច្រើនឆ្នាំកន្លងមក មានរបាយការណ៍ជាច្រើនបានរាយការថា អ្នកទោសស្ត្រីត្រូវបានទទួលរងនូវការរំលោភបៀតបៀនលើរូបកាយក្នុងពន្ធនាគារ។ ក្នុងឆ្នាំ២០០៥ មានរបាយការស្តីពីការរំលោភបំពានលើរូបកាយអ្នកទោសស្ត្រីក្នុងពន្ធនាគារចំនួន ៤៧ ករណី និង ឆ្នាំ២០០៦ (គិតចាប់ពីខែមករា ដល់ ខែតុលា) មានចំនួន ២២ ករណី។ ផ្ទុយទៅវិញ មិនមានរបាយការមកលីកាដូស្តីពីការរំលោភលើផ្លូវភេទ ឬ ការរំលោភសេពសន្ថវៈនោះទេ។ ទោះជាយ៉ាងណាក្តីក្នុងខែ តុលា ឆ្នាំ២០០៥ មានសេចក្តីរាយការណ៍មួយករណី ដែលឆ្មាំពន្ធនាគារត្រូវបានគេចោទប្រកាន់ថាបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនៅក្នុងពន្ធនាគារមួយ ដែលមិនបានឃ្លាំមើលដោយលីកាដូ។ ការរំលោភបៀតបៀនលើផ្លូវភេទទំនងជាត្រូវបានលាក់បិទបាំងយ៉ាងជិតក្នុងពន្ធនាគារ ដោយហេតុផលភ័យខ្លាច ភាពអាម៉ាស់ និងកត្តាចិត្តសាស្ត្រផ្សេងទៀត។ លទ្ធភាពដែលអាចកើតមានការរំលោភបៀតបៀនលើផ្លូវភេទ ការរំលោភសេពសន្ថវៈ និង ការរំលោភបំពានលើរូបរាងកាយផ្សេងៗទៀតនៅតែមានកំរិតខ្ពស់ ជាពិសេសនៅពន្ធនាគារ ដែលអ្នកទោសស្ត្រីត្រូវបានឃ្លាំមើលដោយឆ្មាំពន្ធនាគារបុរស។

## កុមារគ្មានទោសដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយ


ម្តាយជាមួយកូននៅមណ្ឌលអប់រំកែប្រែទី២

ក្នុងខែ កញ្ញា ឆ្នាំ ២០០៦ មានកុមារក្រោមអាយុ ៦ឆ្នាំ ចំនួន ៣៧នាក់ រស់នៅជាមួយម្តាយក្នុងពន្ធនាគារ ដោយរាប់បញ្ចូលទាំងទារកអាយុក្រោមអាយុ ១ ឆ្នាំ ចំនួន ២២នាក់ផងដែរ។ ចំនួននេះបានកើនឡើងជាង កាលពីឆ្នាំមុនដែលមានកុមារត្រឹមតែ ២២ នាក់ប៉ុណ្ណោះ។ អំឡុងឆ្នាំ ២០០៥ និង ឆ្នាំ២០០៦ មានអ្នកទោសស្ត្រី ដែលមានផ្ទៃពោះចំនួនពី ៤ ទៅ ២០ នាក់ក្នុងពន្ធនាគារ ដែលឃ្លាំមើលដោយលីកាដូ។

យោងតាមនីតិវិធីពន្ធនាគារលេខ ៣៤ ចែងថា កុមារអាយុក្រោម ៦ ឆ្នាំត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយម្តាយជាប់ឃុំឃាំងក្នុងពន្ធនាគារ បាននៅពេលដែលគេចាប់គិតថា ការធ្វើបែបនេះ គឺជាឧត្តមប្រយោជន៍ដល់កុមារ[១]។ ប៉ុន្តែ មានកុមារខ្លះអាយុលើស ៦ ឆ្នាំត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយម្តាយដែលជាប់ឃុំឃាំងក្នុងពន្ធនាគារដោយសារតែគ្មានជំរើសផ្សេងទៀត។

ដោយសារតែកុមារអាយុក្រោម ៥ឆ្នាំកំពុងលូតលាស់ខ្លាំងទាំងផ្នែករូបរាងកាយ សង្គម និង ប្រាជ្ញាស្មារតី នីតិវិធីពន្ធនាគារតំរូវឱ្យអាជ្ញាធរពន្ធនាគារផ្តល់ម្ហូបអាហារជាមូលដ្ឋានដល់កុមារ[២]។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងរូបភាពជាក់ស្តែងតំរូវការជាមូលដ្ឋានទាំងនេះ ត្រូវបានគេមិនយកចិត្តទុកដាក់ឡើយ។ ពេលបច្ចុប្បន្ននេះ កុមារដែលរស់នៅក្នុងពន្ធនាគារខ្វះខាតអាហាររូបត្ថម និង ការអប់រំ ដើម្បីឱ្យកុមារលូតលាស់បានសមរម្យ។ លើសពីនេះទៅទៀត កុមារត្រូវរងគ្រោះថ្នាក់ដល់រាងកាយទៀតផង នៅពេលត្រូវបានដាក់ឱ្យនៅជាមួយឧក្រិដ្ឋជនដែលធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋធន់ធ្ងរ ហើយក៏អាចងាយរងការធ្វើបាបពីសំណាក់ឆ្មាំពន្ធនាគារផងដែរ។

[១] នីតិវិធីពន្ធនាគារលេខ ៣៤” ស្ត្រីមានផ្ទៃពោះ និង កុមាររស់នៅក្នុងពន្ធនាគារ” មាត្រា ៣ (២)
[២] នីតិវិធីពន្ធនាគារលេខ ៣៤ មាត្រា ៤ (១)

## ករណីសិក្សាទី ៨: អនីតិជនក្នុងពន្ធនាគារ

*ខ្ញុំបាទឈ្មោះ សុខ លី អាយុ ១៤ ឆ្នាំ ។ ខ្ញុំមានស្រុកកំណើតនៅខេត្តបាត់ដំបង ។ ខ្ញុំរស់នៅក្នុងបន្ទប់ឃុំឃាំងជាមួយអ្នកទោសជាមនុស្សចាស់ចំនួន ២៦នាក់ ។*

*មានអ្នកទោសក្មេង៧ដ៏ទៃទៀតនៅក្នុងពន្ធនាគារនេះដែរ ប៉ុន្តែពួកគេត្រូវបានឃុំនៅក្នុងបន្ទប់ឃុំឃាំងផ្សេងទៀត ។ ការប្រព្រឹត្តិរបស់អាជ្ញាធរពន្ធនាគារមកលើយើងដូចអ្នកទោសជាមនុស្សចាស់ដែរ ។ យើងទទួលបានរបបអាហារ និង ការចេញសំរាកលំហែរដូចមនុស្សចាស់ ហើយវិន័យពន្ធនាគារសំរាប់អ្នកទោសជាមនុស្សចាស់ក៏អនុវត្តចំពោះយើងដែរ ហើយខ្ញុំថែមទាំងប្រឈមមុខនឹងតុលាការដូចអ្នកទោសជាមនុស្សចាស់ដែរ ពេលដែលខ្ញុំត្រូវបានគេកាត់ឱ្យជាប់ទោស ។ ខ្ញុំធ្លាប់គិតថា អាជ្ញាធរប្រហែលជាប្រព្រឹត្តមកលើខ្ញុំមិនដូចជាអ្នកទោសជាមនុស្សចាស់នោះទេ ពីព្រោះខ្ញុំនៅក្មេង ប៉ុន្តែ រឿងបែបនេះមិនកើតឡើងនៅកម្ពុជាទេ ។ អ្នកទោសជាមនុស្សចាស់ខ្លះបានជួយមើលការខុសត្រូវនឹងការពារខ្ញុំមិនឱ្យមានបញ្ហាដែរ ។*

*ខ្ញុំធ្លាប់ឮថា នៅភ្នំពេញមានពន្ធនាគារមួយសំរាប់ដាក់អ្នកទោសជាកុមារ ។ ខ្ញុំចង់ទៅនៅទីនោះប្រសិនបើអាចទៅរួច ។ ខ្ញុំចង់នៅជាមួយក្មេងៗដែលមានអាយុស្របាលគ្នា ពីព្រោះនៅទីនេះយើងពុំមានអ្វីធ្វើច្រើនទេ ហើយបញ្ហាដែលសំខាន់យើងគ្មានឱកាសបានទៅសាលារៀនឡើយ ។ ខ្ញុំធ្លាប់ទៅសាលារៀនមុនពេលខ្ញុំមកកាន់ទីនេះ ។*

*ខ្ញុំមានការភ័យខ្លាចនៅទីនេះពីព្រោះ អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងជាមួយខ្ញុំខ្លះជាឧក្រិដ្ឋជនធ្ងន់ធ្ងរ នឹងជាអ្នកមានអំណាច ដែលធ្លាប់បានចាប់រំលោភនឹងបានសំលាប់មនុស្ស ។ ក្រុមគ្រួសាររបស់ខ្ញុំពុំសូវមកសួរសុខទុក្ខញឹកញាប់ទេ ពីព្រោះពួកគាត់ត្រូវចំណាយលុយច្រើនសំរាប់ការធ្វើដំណើរ នឹងបង់ថ្លៃសុំការអនុញ្ញាតិចូលពន្ធនាគារ ។ ខ្ញុំត្រូវជាប់ទោសចំនួន២ឆ្នាំទៀត ។ វាពិតជាយូរណាស់រហូតដល់ពេលខ្ញុំត្រូវគេដោះលែង ប៉ុន្តែ នៅពេលថ្ងៃនោះមកដល់ ខ្ញុំមិនប្រាកដខ្លួនឯងសោះថាតើខ្ញុំនឹងត្រូវធ្វើអ្វី ។ ខ្ញុំប្រហែលជាវិលត្រលប់ទៅសាលារៀនវិញ ។*

មកទល់ខែតុលា ឆ្នាំ២០០៦ មានអនីតិជនចំនួន ៤៥២ នាក់ ( អាយុចន្លោះពី ១៣ ដល់ ១៨) ក្នុងពន្ធនាគារដែលឃ្លាំមើលដោយលីកាដូ។ មិនមានកុមារអាយុក្រោម ១៣ ឆ្នាំ ត្រូវឃុំឃាំងទេ ដោយសារតែការហាមប្រាម

មិនឱ្យឃុំឃាំងកុមារអាយុក្រោម ១៣ឆ្នាំ (ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤.៤)។[១៥] លីកាដូពុំមានស្ថិតិអនីតិជនក្រោមអាយុ ១៣ ឆ្នាំនៅក្នុងពន្ធនាគារឡើយ។

**ចំនួននអនីតិជនក្នុងពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយ លីកាដូ ពីឆ្នាំ ២០០១-២០០៦**[១៦]




**ចំនួនអនីតិជនក្នុងពន្ធនាគារនីមួយៗ ក្នុងចំណោមពន្ធនាគារទាំង ១៨ ដែលឃ្លាំមើលដោយ លីកាដូ ពីឆ្នាំ ២០០៤-២០០៦**[១៧]

| ពន្ធនាគារ | ២០០៤ | ២០០៥ | មករា-តុលា ២០០៦ |
|---|---|---|---|
| នគរបាលយុត្តិធម៌ (ប៉េហ្ស៊ី) | ១ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី១ (ម-១) | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី២ (ម-២) | ២០០ | ២៨៣ | ២៨៥ |
| ទួលស្លែង | ០ | ០ | ០ |
| មណ្ឌលអប់រំកែប្រែទី៣ (ម-៣) | ០ | ០ | ០ |
| ខេត្តកំពង់ចាម | ១៩ | ២៥ | ៣២ |
| ក្រុងព្រះសីហនុ | ៦ | ១១ | ៦ |

---

[១៥] អាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា(ូណទាជ)-បទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល អនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ក្នុងខែ កញ្ញា ឆ្នាំ១៩៩២។ ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ (មាត្រា ៣៨) ចែងថា" កុមារអាយុតិចជាង ១៣ ឆ្នាំមិនអាចឃុំឃាំងលើសពី ៣៦ ម៉ោងបានទេ។ ហើយមាត្រា ៣៨ ក៏បានហាមឃាត់មិនអោយមានការឃុំឃាំងមនុស្សអាយុក្រោម ១៨ ឆ្នាំនៅកន្លែងឃុំឃាំងនគរបាលលើសពី ៤៨ ម៉ោងផងដែរ។ ច្បាប់ស្ដីពីច្បាប់នីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៃរដ្ឋកម្ពុជានៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៣ ហើយត្រូវបានប្រកាសអោយប្រើប្រាស់ដោយអនុក្រិតលេខ២១ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា។

[១៦] តួរលេខទាំងអស់គិតមកដល់ខែ ធ្នូ លើកលែងតែឆ្នាំ២០០៦ គិតត្រឹមខែ តុលា

[១៧] តួរលេខទាំងអស់គិតមកដល់ខែ ធ្នូ លើកលែងតែឆ្នាំ២០០៦ គិតត្រឹមខែ តុលា

| | | | |
|---|---|---|---|
| ខេត្តកំពង់ស្ពឺ | ៦ | ៧ | ៧ |
| ខេត្តកំពត | ០ | ០ | ២ |
| ខេត្តកំពង់ឆ្នាំង | ៦ | ១២ | ៤ |
| ខេត្តកណ្តាល (តាខ្មៅ) | ១០ | ២១ | ១៤ |
| ខេត្តកំពង់ធំ | ៤ | ៦ | ៥ |
| ខេត្តកោះកុង | ៤ | ០ | ១ |
| ខេត្តពោធិ៍សាត់ | ៣៩ | ១២ | ១៤ |
| ខេត្តបាត់ដំបង | ១៣ | ៣០ | ៤២ |
| ខេត្តបន្ទាយមានជ័យ | ៥ | ២៦ | ២៥ |
| ខេត្តសៀមរាប | ៨ | ៤ | ០ |
| ខេត្តស្វាយរៀង | ៧ | ១០ | ១៥ |
| **សរុប** | **៣២៨** | **៤៤៧** | **៤៥២** |

## ត្រូវឃុំឃាំងអនីតិជនដាច់ដោយឡែកពីមនុស្សចាស់

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ (CROC)[១៨] និងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ[១៩] នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលគួរតែគោរព។ ប៉ុន្តែ ការអនុវត្តន៍ជាក់ស្តែង មាត្រាជាច្រើននៃអនុសញ្ញាត្រូវបានរំលោភ។

មាត្រា ៣៧ (គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ[២០] ក៏បានចែងថាកុមារ ត្រូវដាក់ឱ្យនៅដាច់ពីមនុស្សចាស់នៅក្នុងពន្ធនាគារ ជាពិសេស រាល់កុមារដែលត្រូវបានគេដកហូតសិទ្ធិសេរីភាព ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីមនុស្សចាស់។ គេអាចដាក់កុមារឱ្យនៅជាមួយមនុស្សចាស់បាន ប្រសិនបើគេយល់ថា ការដាក់នោះអាចផ្តល់ឧត្តមប្រយោជន៍ដល់កុមារ។ គេក៏ត្រូវផ្តល់សិទ្ធិដល់កុមារទាំងនោះក្នុងការទាក់ទងជាមួយក្រុមគ្រួសាររបស់គេជានិច្ចតាមរយៈការសរសេរលិខិតឆ្លើយឆ្លង និង ការសួរសុខទុក្ខ និងការជួយសង្គ្រោះក្នុងកាលៈទេសៈដែលចាំបាច់"។

ទោះបីជាយ៉ាងណាក្តី ជាក់ស្តែងអ្នកទោសជាកុមារត្រូវបានគេដាក់ក្នុងបន្ទប់ឃុំឃាំងជាមួយអ្នកទោសជាមនុស្សចាស់ ព្រោះថាពន្ធនាគារតាមបណ្តាខេត្តភាគច្រើនពុំមានបន្ទប់ឃុំឃាំងគ្រប់គ្រាន់សំរាប់ដាក់អ្នកទោសជាកុមារឱ្យនៅដាច់ដោយឡែកពីមនុស្សចាស់ឡើយ។ បញ្ហាមួយទៀត គឺពន្ធនាគារសំរាប់ដាក់អ្នកទោសស្ត្រី និង កុមារ

[១៨] អនុសញ្ញាស្តីពីសិទ្ធិកុមារ។ សេចក្តីសម្រេចមហាសន្និបាតលេខ ៤៤/២៥ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩។

[១៩] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៣។

[២០] មាត្រា ៣៧ (គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

(មណ្ឌលអប់រំកែប្រែទី២) ត្រូវបានគេចាត់ទុកថា ជាពន្ធនាគារដែលមានស្ថានភាពល្អប្រសើរជាងពន្ធនាគារដទៃទៀត ។ ហេតុដូច្នេះ អ្នកទោសជាយុវជនខ្លះបានអះអាងដោយកុហកថា ពួកគេមានអាយុក្រោម ១៨ ឆ្នាំ។ នៅកម្ពុជា បញ្ហាទាំងនេះបានក្លាយជារឿងសាមញ្ញ ចំពោះអ្នកដែលពុំដឹងអាយុរបស់ខ្លួនពិតប្រាកដ ជាពិសេសអ្នកដែលមានកំណើតនៅជនបទ ឬ កង្វះលិខិតបញ្ជាក់ផ្លូវការដូចជា សំបុត្រកំណើត។ ពិសេសជាងនេះទៅទៀតមានករណីកើតឡើងជាញឹកញាប់ដោយអាយុរបស់អ្នកទោសត្រូវបានកំណត់ដោយមន្ត្រីប៉ូលីស ដែលចាប់ខ្លួនពួកគេតាមរយៈការប៉ាន់ស្មានតាមការភិនភាគមុខមាត់។ មានរបាយការណ៍មិនច្បាស់ការមួយ ថាមានអ្នកទោសពេញវ័យអាយុជាង ២០ឆ្នាំ រស់នៅក្នុងមណ្ឌលអប់រំកែប្រែទី២។

## ការប្រព្រឹត្តិនៅក្នុងពេលជាប់ឃុំឃាំងបណ្តោះអាសន្ន

មាត្រា ១៤ (៤) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា" អនីតិជនដែលមានអាយុក្រោម ១៣ឆ្នាំ មិនត្រូវដាក់ក្នុងកន្លែងឃុំឃាំងបណ្តោះអាសន្ននោះទេ ហើយអនីតិជនអាយុពី ១៣-១៨ ឆ្នាំ មិនត្រូវយកទៅដាក់ក្នុងកន្លែងឃុំឃាំងបណ្តោះអាសន្នលើសពី១ខែបានទេ "។ មាត្រានេះ ក៏ចែងផងដែរថារយៈពេលអាចត្រូវបានបន្ថែមដល់ទៅ ២ខែ ប្រសិនបើអនីតិជននោះត្រូវបានចោទប្រកាន់ដោយបទឧក្រិដ្ឋធ្ងន់ធ្ងរ (មិនមែនជាបទល្មើសមជ្ឈិម)។ តាមភាពជាក់ស្តែងនៅពន្ធនាគារកម្ពុជា អនីតិជនត្រូវបានគេឃុំឃាំងបណ្តោះអាសន្នលើសពីរយៈពេលកំណត់ ២ខែ ហើយអនីតិជនខ្លះត្រូវបានឃុំឃាំងបណ្តោះអាសន្នដល់ទៅ ១ឆ្នាំ។



*អនីតិជននៅពន្ធនាគារតាខ្មៅ*

### យុត្តិធមិយុវជន

មាត្រា៤០ (៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ[២១] ចែងថារដ្ឋជាដៃគូនានា ត្រូវប្រឹងប្រែងបង្កើតច្បាប់ នីតិវិធីអាជ្ញាធរ និងស្ថាប័ន ដែលអនុវត្តជាពិសេសចំពោះកុមារដែលត្រូវចោទប្រកាន់ជាប់ចោទ ឬ ទទួលស្គាល់ថាគេបានរំលោភច្បាប់ព្រហ្មទណ្ឌ" ។ មកទល់ពេលនេះ កម្ពុជាពុំទាន់មានប្រព័ន្ធយុត្តិធមិសំរាប់យុវជននៅឡើយទេ។ កម្ពុជាពុំទាន់មានតុលាការយុវជន និង មន្ទីរឃុំឃាំងសំរាប់យុវជន ដែលរំលោភច្បាប់ដាច់ដោយឡែកនៅឡើយទេ ហើយពុំមានជំរើសណាក្នុងឃុំឃាំងយុវជនផងដែរ។

[២១] មាត្រា ៤០ (៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

យោងតាមមាត្រា ៧៥ និង ៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ[២២] បានចែងថា "ពេលដែលជនជាប់ចោទចូលខ្លួនជាលើកដំបូង ចៅក្រមស៊ើបអង្កេតតំរូវឱ្យប្រាប់ជនជាប់ចោទនោះពីសិទ្ធិរបស់គេ" ។ មាត្រានេះបានចែងទៀតថា "ចៅក្រមស៊ើបអង្កេតត្រូវតែផ្អាកការសួរចំលើយរហូតដល់ជនជាប់ចោទមានមេធាវី" ។ មាត្រា ៧៦ ក៏បានចែងថា "មេធាវីត្រូវតែចាត់តាំងដោយឯករាជ្យដោយចៅក្រម ពេលណាជនចាប់ចោទ ដែលជាអនីតិជនគ្មានមេធាវីការពារ" ។ ប៉ុន្តែករណីខ្លះ អនីតិជនដែលជាប់ចោទពុំទទួលបានមេធាវីការពារក្តីនៅពេលសវនការទេ ។

មាត្រា ៦៨ (២) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល[២៣] បានគូសបញ្ជាក់អំពីស្ថានភាពជាក់ស្តែងដែលទោសគួរតែត្រូវបន្ធូរបន្ថយ ។ យោងតាមមាត្រានេះ ជនចាប់ចោទដែលមានអាយុតិចជាង ១៨ឆ្នាំ ទណ្ឌកម្មចំពោះពួកគេគួរតែត្រូវកាត់បន្ថយពាក់កណ្តាល ។ តាមបទពិសោធន៏កន្លងមកបានបង្ហាញថា ចៅក្រមជាទូទៅបានអនុវត្តតាមបញ្ញត្តិនេះ ។

## តើលីកាដូកំពុងបម្រើសេវាអ្វីខ្លះ?




ក្នុងអំឡុងឆ្នាំ ២០០៣ លីកាដូ បានបង្កើននូវកម្មវិធីផ្តល់ជំនួយដល់ទារក កុមារ និង ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ ។ កម្មវិធីនេះ ជួយសំរបសំរួលពីសាធារណៈជន និង អង្គការមនុស្សធម៌ក្នុងការផ្តល់ជំនួយដល់ក្រុមងាយរងគ្រោះក្នុងពន្ធនាគារ ។ នៅក្នុងខែតុលា ឆ្នាំ២០០៦ មានសាធារណៈជន និងអង្គការចំនួន ១៣ បានរួមគ្នាផ្តល់ជំនួយមនុស្សធម៌ដល់ពន្ធនាគារចំនួន ១០ ដែលមានអ្នកទោសដែលមានកូននៅជាមួយ ។

អំឡុងឆ្នាំ ២០០៥-២០០៦ កម្មវិធីនេះបានផ្តល់ជាអាហារ សម្ភារៈផ្សេងៗ និង ជំនួយផ្នែកវេជ្ជសាស្ត្រដល់កុមារ ឪពុក ម្តាយកុមារ និង ស្ត្រីមានផ្ទៃពោះដែលកំពុងរស់នៅក្នុងពន្ធនាគារក្នុងប្រទេសកម្ពុជា ។ ជាឧទាហរណ៍អ្នកដែលជួយឧបត្ថម្ភមានដូចខាងក្រោមនេះ:

---

[២២] ដូចមាត្រា ៧៥ និង ៧៦

[២៣] មាត្រា ៦៨ (២) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

- ស្ថានទូតម៉ាល់តាចូលសួរសុខទុក្ខស្ត្រី និង កុមារនៅមណ្ឌលអប់រំកែប្រែទី២ រៀងរាល់កន្លះខែម្តង។ សម្ភារៈដែលផ្តល់ជូនរួមមានដូចជា ម្ហូបអាហារ ចាន មុង សម្ភារៈអានាម័យ សម្លៀកបំពាក់ និង ថ្នាំពេទ្យ ដល់ស្ត្រីមានផ្ទៃពោះ និង ឪពុកម្តាយដែលមានកូននៅជាមួយ ។ ការផ្តល់ជូននេះ បានបន្តធ្វើជារៀងរហូតចាប់តាំងពីឆ្នាំ ២០០២មក ។
- អង្គការ NAAA Cambodia (អង្គការរបស់ប្រទេសអ៊ីតាលី) បានផ្តល់ជំនួយដល់កុមារ ឪពុកម្តាយកុមារ និង ស្ត្រីដែលមានផ្ទៃពោះនៅពន្ធនាគារខេត្តសៀមរាបរាល់ពីរសប្តាហ៍ម្តង។ ជំនួយទាំងនោះរួមមានអាហារ មុង សម្ភារៈអនាម័យ សំលៀកបំពាក់ ប្រដាប់ប្រដារក្មេងលេង ជំនួយបរិក្ខាផ្នែកវេជ្ជសាស្ត្រ និង សម្ភារៈ ផ្សេងៗទៀត ។ ជំនួយទាំងនេះបានផ្តល់ជូនចាប់តាំងពីឆ្នាំ ២០០៥ ។
- អង្គការលើកលែងទោសអន្តរជាតិ Townsville នៅប្រទេសអូស្ត្រាលី បានផ្តល់ជំនួយដល់កុមារ ឪពុកម្តាយកុមារ និង ស្ត្រីមានផ្ទៃពោះនៅពន្ធនាគារខេត្តស្វាយរៀងរាល់មួយខែម្តង។ សម្ភារៈទាំងនោះ មានដូចជា អាហារ និង សម្ភារៈផ្សេងទៀត ការផ្តល់ជំនួយនេះបានចាប់ផ្តើមតាំងពីឆ្នាំ ២០០៦។

ការព្រួយបារម្ភណ៍ខ្លាំងបំផុតចំពោះកុមារ និង ស្ត្រីមានផ្ទៃពោះទាក់ទងនឹងបញ្ហាអាហាររូបត្ថម្ភ និង ទឹកស្អាត។ កម្មវិធីនេះ ផ្តោតលើការព្រួយបារម្ភណ៍ចំពោះបញ្ហាកង្វះការសិក្សាអប់រំ និង ឱកាសអភិវឌ្ឍន៍សំរាប់កុមារដែលជាប់ឃុំឃាំង កម្មវិធីនេះក៏កំពុងរៀបចំគំរោងជាក្នុងដំណាក់ការទី២ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។[២៤]

[២៤] សំរាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ សូមមើលនៅក្នុងគេហទំព័ររបស់លីកាដូ: www.licadho.org/programs/adoptaprison.php